ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង

**ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី១៩)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី
លោក លឹម ស៊ុយហុង
លោក ម៉ាតូ គ្រីស្តារ
*(Mr. Matteo Crippa)*
លោកស្រី សែ កុលវុឌ្ឍី
កញ្ញា ណាថាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ ប៊េត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទួអាត ហ្វដ *(Mr. Stuart FORD)*

លោក ប៉ាក់ ចន្ទលីណូ

**មេធាវីការពារជនជាប់ចោទ កាំង ហ្កេក អ៊ាវ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យ៉ុង ផានិត

លោក គីម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃីស្ទូត ហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ *(Mr. Alain Werner)*

លោកស្រីអេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សីជំនាញ** ៖ លោក ក្រេក អេតឆេសាន់

សួរដោយ លោក តាន់ សេណារ៉ុង.......................................................................ទំព័រ ៤៣
សួរដោយ លោក អាឡិចសាន់ឌឺ បេ៊ត បន្តពី...............................................................ទំព័រ ៥៦

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊េត | អង់គ្លេស |
| លោក គ្រេក អេតធេសាន់ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវឺរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| លោកស្រី ស៊ីលឃិ ស្ទូតហ្សីនស្គី | អង់គ្លេស |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:១៧:៥៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ។ ក្រឡាបញ្ជីសវនាការឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីត្រូវចូលក្នុងដំណើរការសវនាការនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលបានចូលរួមនៅក្នុងដំណើរនីតិវិធីសវនាការក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួនហើយ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនដែលបានចូលរួមនៅក្នុងសាលសវនាការនេះបានជ្រាបថា ជាកិច្ចបន្តនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការជាសម្ងាត់ដើម្បីរៀបចំដំណើរការសវនាការ ដែលប៉ុន្មានថ្ងៃនេះ មានបញ្ហាលើកឡើងរវាងភាគីនានា ពាក់ព័ន្ធនៅក្នុងរឿងក្តី ។

ដូច្នេះដើម្បីឲ្យដំណើរការនេះបានល្អ គឺអង្គជំនុំជម្រះសម្រេចធ្វើសវនាការជាសម្ងាត់ ហើយនៅក្នុងដំណើរការសវនាការជាសម្ងាត់នេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺមិនអនុញ្ញាតឲ្យចូលរួមនៅក្នុងដំណើរការសវនាការនេះទេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំយល់ថាមានបញ្ហានៅក្នុងការបកប្រែ ។ អ្វីចឹងអ្វីដែលយើងបានឮហ្នឹង គឺមិនឮពីសវនាការទេ ប៉ុន្តែរឿងអំពីការរៀបចំការគ្រប់គ្រងសវនាការ ហើយដែលសាធារណជនមិនអនុញ្ញាតឲ្យចូលរួម ហើយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដូច្នេះដែរ ។ ពីព្រោះអីថា គឺដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវចូលរួមទេនៅវេលាព្រឹកនេះ ចំពោះសវនាការអសាធារណៈនេះ ។

**ប្រធានអង្គជំនុំ៖**

ដំណើរការនេះនឹងអាចប្រព្រឹត្តទៅប្រហែលជាអំឡុងមួយម៉ោង ឬមួយម៉ោងកន្លះ ។

មន្ត្រីតុលាការ គឺចាត់ការបិទវាំងនន ហើយអ្នកបច្ចេកទេសធ្វើការផ្តាច់នូវព័ត៌មាន ដែលអាច

ចេញទៅខាងសាធារណៈ ។

[០៩:២២:៣៥]

ឥឡូវនេះ យើងដំណើរការប្រព្រឹត្តទៅក្នុងអំឡុងពេល--

អញ្ជើញលោកស្រី មានបញ្ហាអីទៅ? ចាប់ឡើងមានបញ្ហាមុនពេលដំណើរការទៀត ។

**អ្នកបកប្រែ៖**

លោកចៅក្រម លោកប្រធាន ក្រុមអ្នកបកប្រែនេះអត់មានរូបភាពចេញមកពីបន្ទប់សវនាការទេ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ខាងអ្នករូបភាពតែខាងសាធារណជនទេ តែចំណែកឯខាងអ្នកបកប្រែម៉េចក៏អត់មានរូបភាពដែរ? បញ្ជូនរូបភាពទៅខាងអ្នកបកប្រែ ។

[០៩:២៤:៥៣]

**អ្នកបកប្រែ៖**

លោកប្រធានឥឡូវនេះ ខាងក្រុមអ្នកបកប្រែអាចមើលឃើញរូបភាពហើយ សូមអរគុណ ។

*[សវនាការអសាធារណៈពីម៉ោង០៩:៣១នាទី ដល់ម៉ោង ១១:២៨ នាទី*

*គឺពីទំព័រ៣ ដល់ទំព័រ៣៧ ត្រូវបានដកចេញ]*

[១២:០១:០៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះសាលាដំបូងសូមធ្វើការប្រកាស ផ្សាយអំពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សារៀបចំកិច្ចដំណើរការសវនាការដែលបានធ្វើ ។

អស់រយៈពេលពេញមួយព្រឹក ព្រឹកមិញនេះ អង្គជម្រះ និងភាគីទាំងអស់ដែលបានចូលរួមសុទ្ធបានតែបានចញ្ចេញមតិយោបល់របស់ខ្លួន នូវក្នុងការជជែកពិភាក្សារកដំណោះស្រាយនៅបញ្ហាដែលបានកើតមាន ជំទាស់នៅក្នុងដំណើរការប្រព្រឹត្តទៅកាលពីប៉ុន្មានថ្ងៃមុននេះ ហើយជាលទ្ធផលបានទទួលដូចខាងក្រោមនេះ៖

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្តីបានទទួលស្គាល់នូវភាពជំនាញរបស់បណ្ឌិត ក្រេក អេតធេសាន់ ហើយគាត់មិនជំទាស់ទៅនឹងរបាយការណ៍របស់អ្នកជំនាញទេ និងមេធាវីការពារក្តីក៏បានទទួលស្គាល់ផងដែរ នូវរបាយការណ៍ព្រមទាំងឯកសារភ្ជាប់ជាឧបសម្ព័ន្ធអាចត្រូវយកមកពិចារ-ណាថា បានលើកយកមកពិភាក្សាដេញដោលនៅចំពោះមុខតុលាការស្របតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង។ ទោះជាយ៉ាងនេះក៏ដោយភាគីដទៃទៀតមានសិទ្ធិជំទាស់ទៅលើរបាយការណ៍ ឬនិងឯកសារជាឧបសម្ព័ន្ធដែលភ្ជាប់ទៅនឹងរបាយការណ៍នោះ ដើម្បីឱ្យអង្គជំនុំជម្រះអាចធ្វើសេចក្តីសម្រេចអំពីបញ្ហានោះបាន ។ ដូច្នេះ ជាលទ្ធផល យើងមិនចាំបាច់អានរាល់សេចក្តីសង្ខេបនៃឯកសារនីមួយៗ ដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធនោះទេ ។ តុលាការនឹងពិចារណាលើឯកសារដែលប្រមូលផ្តុំនៃរបាយការណ៍ដែលបានលើកយកមកពិភាក្សាដេញដោល ស្របតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង តាមមធ្យោបាយសង្ខេបដែលធ្វើឡើងដោយអ្នកជំនាញ ក្រេក អេតធេសាន់ ។

ឥឡូវនេះ ដោយសារដល់ម៉ោងត្រូវឈប់សម្រាកពិសាអាហារថ្ងៃត្រង់ផង អង្គជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំហើយឱ្យនាំគាត់មកកាន់សាលសវនាការវិញនៅម៉ោងមួយនិងសាមសិបនាទី ហើយភាគីដែលពាក់ព័ន្ធក៏ដូច្នោះដែរ សូមអញ្ជើញឱ្យបានមុនម៉ោងកំណត់ ។ ហើយមន្ត្រីតុលាការសម្រួលដល់អ្នកជំនាញ ដើម្បីឱ្យគាត់បានអញ្ជើញគាត់មកកាន់សាលសវនាការនៅម៉ោងមួយសាមសិបនាទី ក្រោយអាហារថ្ងៃត្រង់រួច។

*[សវនាការសម្រាកនៅម៉ោង ១២:០៧នាទី ដល់ម៉ោង ១៣:៣៥ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងចាប់ផ្តើមនេះ អង្គជំនុំជម្រះ សូមជម្រាបសួរទៅមេធាវីការពារជនជាប់ចោទ ថាតើសេចក្តីប្រកាសពីលទ្ធផលនៃកិច្ចពិភាក្សាកាលពីព្រឹកមិញ តើលោកមានអ្វីត្រង់កត់សម្គាល់ដែរឬទេ? ឬក៏គ្មានទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន ។ មេធាវីសូមបញ្ជាក់ថា គឺជាកិច្ចការមួយដែលបានខំប្រឹងប្រែងដ៏ផុសផុលក្នុងការអនុញ្ញាតឲ្យនីតិវិធីនេះដំណើរការទៅមុខ នៅក្រោមលក្ខខណ្ឌដែលអាចអនុវត្តទៅបាន។ ដោយសារតែមូលហេតុនេះ ខាងមេធាវីការពារក្តីបានចង្អុលបង្ហាញថា ខ្លួនទទួលយកគុណសម្បត្តិ និងសមត្ថភាពរបស់លោក ក្រេក អេតឆេសាន់ ជាអ្នកជំនាញ គឺទទួលស្គាល់រហូតដល់ថ្ងៃទី-- ឯកសារទាក់ទងទៅនឹងលោក ក្រេក អេតឆេសាន់ ដល់ខែកក្កដា ឆ្នាំ២០០៧ ហើយនិងកាលបរិច្ឆេទចំពោះឧបសម្ព័ន្ធដែលបានភ្ជាប់ជាមួយរបាយការណ៍នៅក្នុងឯកសារនោះ ។

មេធាវីការពារក្តី ដូច្នេះ បានបញ្ជាក់ថាខ្លួនយល់ស្របក្នុងការពិចារណាថា ឯកសារទាំងនោះគឺយកមកប្រើប្រាស់ដើម្បីជាមូលដ្ឋាននៃរបាយការណ៍នោះ ហើយជាពិតរបាយការណ៍និងឯកសារដែលយើងនឹងធ្វើការពិភាក្សាដេញដោលនៅក្នុងសវនាការនេះ គឺហ្នឹងបញ្ចូលនៅក្នុងរឿងអនុលោមតាមវិធាន ៨៧ ។ ប៉ុន្តែ មេធាវីការពារក្តី សូមទទូចចំពោះអង្គហេតុទាំងឡាយដែលមានក្រោយខែកក្កដា ឆ្នាំ២០០៧ ដែលលោក ក្រេក អេតឆេសាន់ បានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការចោទប្រកាន់ចំពោះជនជាប់ចោទនោះ ។ នៅក្រោមលក្ខខណ្ឌនេះចម្លើយរបស់គាត់ជាអ្នកជំនាញមិនត្រូវផ្អែកទៅលើអំឡុងពេល បន្ទាប់ពីការបរិច្ឆេទខែកក្កដា ឆ្នាំ២០០៧ នោះទេ ។ ទៅលើអង្គហេតុដែលគាត់បានដឹងក្រោយពីខែកក្កដា ឆ្នាំ ២០០៧ ។ ដូច្នេះ មេធាវីការពារក្តី សូមរំឭកថាគោលការណ៍ដែលបានប្រកាសដោយតុលាការអឺរ៉ុបស្តីពីផ្នែកសិទ្ធិមនុស្សនោះ បាននិយាយថា វាមិនគ្រប់គ្រាន់សម្រាប់ការរកយុត្តិធម៌នោះទេ ។ ប៉ុន្តែ វាចាំបាច់ក្នុងការឲ្យសាធារណជន គាត់ទទួលស្គាល់នឹងបានដឹងផងថាយុត្តិធម៌ត្រូវបានស្វែងរកក្នុងវិធីដោយយុត្តិ-ធម៌ ។ គ្មានបុគ្គលណាមួយគាត់បានយល់ថា លោក អេតឆេសាន់ ដែលជាសមាជិករបស់ក្រុមសហព្រះរាជអាជ្ញា អាចមានមុខងារជាអ្នកជំនាញ ហើយនិយាយអំពីឯកសារស៊ើបអង្កេត ។ ដូច្នេះហើយ មេធាវីការពារក្តី សូមធ្វើការបែងចែកអំពីអំឡុងពេលរហូតមកដល់ពេលខែកក្កដា ឆ្នាំ២០០៧ ចំពោះ

អំឡុងពេលនេះ អត់មានបញ្ហាទេ ទោះបីជាលោក គ្រេក អេតឆេសាន់ ធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញាក៏ដោយ ។ ដោយសារតែនៅពេលនោះអត់មានការចោទប្រកាន់ ហើយរបាយការណ៍នៅពេលនោះ គឺជារបាយការណ៍ទូទៅហើយវាមានភាពចាំបាច់សម្រាប់ដំណើរការក្តីរបស់យើង ។ ដូច្នេះហើយយើងខ្ញុំសូមធ្វើការបែងចែកក្នុងអំឡុងពេលហ្នឹង គឺពីពេលរហូតមកដល់ខែកក្កដា ឆ្នាំ២០០៧ ហើយអំឡុងពេលមួយទៀតនោះគឺបន្ទាប់ពីខែកក្កដា ឆ្នាំ២០០៧ ។ គឺយើងនឹងមានសហព្រះរាជអាជ្ញាធ្វើការតាំងសំណួរទៅលើលោក គ្រេក អេតឆេសាន់ បន្ទាប់ពីកាលបរិច្ឆេទខែកក្កដា ឆ្នាំ២០០៧ ។

[១៣:៤១:៤៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានមានការកត់សម្គាល់នេះ ហើយបានសហការជាមួយនឹងអង្គជំនុំជម្រះ ដែលអាចធ្វើឱ្យដំណើរការប្រព្រឹត្តទៅក្នុងការសួរដេញដោលបន្តទៅទៀតបាន ដំណើរការ ។ មានបញ្ហាអីទៀត? បញ្ហាដដែលគឺត្រូវបញ្ចប់ មិនឱ្យលើកឡើងទេទៀត ។ បើមានបញ្ហាថ្មីផ្សេងទៀតអាហ្នឹងអាចលើកឡើងបាន ប៉ុន្តែ ដូចជាមិនមានរឿងអីត្រូវលើកនៅពេលនេះទេ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

លោកប្រធាន ខ្ញុំចង់ធ្វើការសង្កេតដោយផ្ទាល់មាត់នៅទីនេះ ជាសាធារណៈអំពីការដក ការមិនអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមកាលពីព្រឹកមិញ ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីអង្គសវនាការឱ្យខ្ញុំបានធ្វើការសន្ទដ្ឋានដោយផ្ទាល់មាត់ចំពោះបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ពីព្រោះយើងបានសន្យាកាលពីព្រឹកមិញនេះហើយ គឺមេធាវីអាចធ្វើបាន ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ ព្រឹកមិញនេះ នៅពេលដែលយើងចាប់ផ្តើមសវនាការ លោកប្រធាននិងអង្គសវនាការបានប្រកាសថា យើងចាប់ផ្តើមនីតិវិធីរបស់យើងជាអសាធារណៈ ហើយដើមបណ្តឹងរដ្ឋប្បវេណីមិនអនុញ្ញាតឱ្យចូលរួម ។ ហើយនៅពេលនោះ គឺខ្ញុំឃើញដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមានរួចហើយ ប៉ុន្តែគាត់នៅខាងក្រៅបន្ទប់សវនាការ ។ ហើយនៅក្នុងសវនាការអសាធារណៈខ្ញុំបានស្នើសុំអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួម ប៉ុន្តែ សំណើនោះត្រូវបានបដិសេធចោល ។ ខ្ញុំបានសង្កេតឃើញផងដែរថា ជនជាប់ចោទគឺបានចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីព្រឹក

មិញ ។ ដើមបណ្តឹងរដ្ឋប្បវេណីជាភាគីនៅក្នុងករណីនេះ គឺមានសិទ្ធិដូចគ្នាទៅនឹងជនជាប់ចោទ បានន័យថាមានសិទ្ធិក្នុងការចូលរួមនៅក្នុងសវនាការរៀបចំផ្សេងៗ ដូចជាសវនាការរៀបចំកាលពីព្រឹកនេះ ហើយមានសិទ្ធិក្នុងការតាមដានសវនាការ ទោះបីក្នុងសវនាការជាអសាធារណៈក៏ដោយ ។ ដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្ញុំបាននិយាយជាមួយកាលពីពេលឈប់សម្រាកនោះ បានធ្វើការតវ៉ាថា បានធ្វើការតវ៉ា ហើយមានបំណងៗនៅក្នុងថ្ងៃអនាគតគឺសុំចូលរួមនៅក្នុងសវនាការបែបនោះដែរ ។ ទោះបីជាសវនាការនោះជាសវនាការផ្អែកទៅលើបច្ចេកទេសក៏ដោយ ។ ប៉ុន្តែ សវនាការដោយពិភាក្សាទៅលើបញ្ហាបច្ចេក-ទេសនោះ គឺវាជាប់ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។ ហើយដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់មានបំណងក្នុងការចូលរួមតាមដានដំណើរការក្តីទាំងមូលផងដែរ រួមទាំងសវនាការអសាធារណៈ ។ ពួកគាត់ទទួលគឺអាចទទួលស្គាល់ចំពោះការមិនចូលរួម ប្រសិនបើមានការចូលរួមក្នុងចំណោមលោកចៅក្រម គឺមានចៅក្រម សហព្រះរាជអាជ្ញា មេធាវី និងក្រឡាបញ្ជីជាដើម។ ប៉ុន្តែ នៅពេលព្រឹកមិញ គឺយើងឃើញថាជនជាប់ចោទ ប្រសិនបើជនជាប់ចោទអនុញ្ញាតឲ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយនោះ គឺ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក៏ស្នើសុំចូលរួមផងដែរ ។

[១៣:៤៦:២៦]

ដូច្នេះ នេះគឺជាសំណើរបស់ខ្ញុំដែលស្នើសុំឲ្យមានការចូលរួម ប៉ុន្តែ ត្រូវបានបដិសេធចោល ។ ប៉ុន្តែ ខ្ញុំគិតថានៅពេលខាងមុខ គឺអង្គសវនាការគួរតែកត់សម្គាល់លើបញ្ហានេះថា ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងអ្នកដែលចូលរួមក្នុងនីតិវិធីនេះ តាំងពីថ្ងៃដំបូងមក គឺគាត់មានផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងការចូលរួមក្នុងដំណើរការក្តីនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការ ។ អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ខ្ញុំសុំធ្វើការសង្កេតមួយ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិរបស់ជនជាប់ចោទគឺមិនដូចគ្នាបេះបិទនោះទេ ។ ហើយយើងឃើញច្បាស់ថា ជនជាប់ចោទត្រូវតែចូលរួមនៅគ្រប់បញ្ហាដែលពាក់ព័ន្ធនឹងគាត់ ។ ប៉ុន្តែ នៅក្នុងនាមការពារក្តី ខ្ញុំសូមធ្វើការគាំទ្រសេចក្តីសន្និដ្ឋាន និងដាក់ជូនរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ខ្ញុំជឿថា តាមអ្វីដែលយើងអាចធ្វើទៅបានដើមបណ្តឹងរដ្ឋប្បវេណីគួរតែត្រូវបានអនុញ្ញាតឲ្យធ្វើការចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការផងដែរ ។ ដោយយើងបញ្ជាក់

ប្រាប់គាត់ថា នៅក្នុងសវនាការអសាធារណៈគឺដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ គឺត្រូវគោរពគោលការណ៍សម្ងាត់ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត បង្គាប់ឲ្យមន្ត្រីតុលាការអញ្ជើញ បណ្ឌិត គ្រេក អេតឆេសាន់ អ្នកជំនាញមកកាន់សាលសវនាការ ដើម្បីធ្វើការសួរដេញដោល ។

ជាកិច្ចបន្តនេះអង្គជំនុំជម្រះសុំប្រគល់វេទិកានេះ ទៅតំណាងសហព្រះរាជអាជ្ញាដើម្បីធ្វើការសួរដេញដោលចំពោះអ្នកជំនាញ ។ សូមអញ្ជើញ ។

[១៣:៥០:០៧]

**លោក តាន់ សេណារ៉ុង៖**

អរគុណ លោកប្រធានអង្គជំនុំជម្រះ ។ មុននឹងខ្ញុំចាប់ផ្តើមសួរសំណួរ ទៅអ្នកជំនាញបណ្ឌិតដែលមានបណ្ឌិត អេតឆេសាន់ នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះ ដើម្បីធ្វើការឲ្យអ្នកជំនាញហ្នឹងបញ្ជាក់នូវឈ្មោះដែលអ្នកជំនាញនោះបាន កាលពីអាទិត្យពីរថ្ងៃមុន អ្នកជំនាញហ្នឹងហាក់ដូចជាបាននិយាយឈ្មោះរបស់អ្នកតស៊ូមួយចំនួន ដែលខ្ញុំស្តាប់បានទាំងសហការីរបស់ខ្ញុំខ្មែរ និងជនបរទេសក៏បានកត់សម្គាល់ឃើញថាអ្នកជំនាញបណ្ឌិត អេតឆេសាន់ ហ្នឹងគាត់បានប្រើឈ្មោះដែលមានឈ្មោះ កែវ មាស គាត់ថាហៅថា អាចារ្យ កង ។ ដូច្នេះក្នុងន័យនេះខ្ញុំសូមការអនុញ្ញាតពីលោកជាមុនថាសុំឲ្យគាត់ធ្វើការបញ្ជាក់ឡើងវិញ ថាតើ កែវ មាស ហ្នឹងហៅ អាចារ្យកង អ៊ីចឹងមែនទេ? ពីព្រោះតាមឯកសារមួយចំនួនវាហាក់ដូចជា នៅពេលដែលអ្នកជំនាញបានលើកពីឈ្មោះហ្នឹងវាធ្វើឲ្យមានការភ័ន្តច្រឡំ ហើយនឹងអ្វីដែលការិយាល័យសហព្រះរាជអាជ្ញាខាងខ្ញុំហ្នឹងគឺថាបានធ្វើការតាមដាន ហើយនិងបានសិក្សាកន្លងមក ថាតើអ្នកជំនាញនៅតែប្រាកដថា អាចារ្យ កែវ មាស គឺជាអាចារ្យ កង ឬ? នៅតែរក្សាថា កែវ មាស អាចារ្យ កង ដដែលឬ? ពីព្រោះឯកសារវាធ្វើឲ្យខាងខ្ញុំហ្នឹងមានការភ័ន្តច្រឡំ ហើយសុំឲ្យគាត់ធ្វើការបញ្ជាក់នូវឈ្មោះនោះឡើងវិញ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកបណ្ឌិត តើអាចបញ្ជាក់បញ្ហានោះវិញបានទេ? បញ្ហានោះគ្រាន់តែបញ្ជាក់អំពីឈ្មោះ កែវ មាស ហៅអាចារ្យ កង គឺជាមនុស្សតែមួយ ដូច្នេះមែនទេ? ឬក៏មានលក្ខណៈខុសគ្នា? គ្រាន់តែបញ្ជាក់ពីបញ្ហានេះទេ ព្រោះអាចមានការភ័ន្តច្រឡំលើបញ្ហានេះ ។

**លោក គ្រេក អេតធេសាន់៖**

ពិតប្រាកដណាស់លោកប្រធាន ។ ខ្ញុំជឿថា នេះជាឈ្មោះត្រឹមត្រូវ ។ កែវ មាស គឺជាអ្នកតស៊ូបដិវត្តន៍ ហើយគាត់ក៏ជា សមាជិក របស់មជ្ឈិមបក្សតាំងពីទស្សវត្សរ៍ទី៦០ មកម្ល៉េះ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** សំណួររបស់ខ្ញុំនេះចង់ឲ្យលោកបញ្ជាក់ថា កែវ មាស ហៅអាចារ្យ កង ឬក៏ កែវ មាស វាដោយឡែកពីឈ្មោះអាចារ្យ កង ។ ពីព្រោះតាមការដែលលោកបានបញ្ជាក់ពីពីរថ្ងៃមុននោះ លោកបានបញ្ជាក់ថា កែវ មាស ហ្នឹងហៅអាចារ្យ កង ។ ដូច្នេះ វាធ្វើឲ្យមានការភ័ន្តច្រឡំនូវការសិក្សាឯកសារកន្លងមករបស់ការិយាល័យសហព្រះរាជអាជ្ញាហ្នឹង នៅពេលដែលបានឮថា លោកបានបញ្ជាក់ថា កែវ មាស ហៅអាចារ្យ កង ។

**ឆ៖** ប្រសិនបើអង្គសវនាការអនុញ្ញាតឲ្យខ្ញុំមានពេលបន្តិច ខ្ញុំនឹងពិនិត្យមើលទៅលើចំណុចមួយដែលទាក់ទងទៅនឹងសំណួរនេះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន នៅក្នុងឱកាសនេះខ្ញុំចង់ធ្វើការរំឭកបន្តិចថា ប្រសិនបើយើងអាចធ្វើទៅរួច ចង់ឲ្យធ្វើការបញ្ចាំងឈ្មោះនៅលើអេក្រង់ នៅពេលដែលឈ្មោះណាមួយត្រូវបានសាក្សីលើកឡើង ។ ខ្ញុំសុំឲ្យអង្គសវនាការទទួលយកនូវសំណើនេះ ពីព្រោះនេះជាចំណុចមួយដែលជាអត្ថប្រយោជន៍ដល់ភាគីពាក់ព័ន្ធទាំងអស់ ។ ពីព្រោះនៅពេលដែលនិយាយឈ្មោះឡើង ខ្ញុំចង់ឲ្យក្រឡាបញ្ជីធ្វើការវាយឈ្មោះនោះបញ្ចូលទៅក្នុងកុំព្យូទ័រហើយបញ្ចាំងនៅលើអេក្រង់ ខ្ញុំយល់ថា នេះប្រហែលជាមិនមែនជាបញ្ហាបច្ចេកទេសដ៏ស្មុគស្មាញពេកនោះទេ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** តំណាងអយ្យការចង់សុំឲ្យលោកបញ្ជាក់ថា តើ កែវ មាស ហៅអាចារ្យ កង ជាមនុស្សតែមួយ ឬជាមនុស្សផ្សេងគ្នា? គ្រាន់តែចង់ឲ្យលោកបញ្ជាក់ប៉ុណ្ណឹងឡើងវិញទេបាទ ។

**ឆ៖** ពិតហើយលោកសហព្រះរាជអាជ្ញា ។ តាមការយល់ដឹងរបស់ខ្ញុំ លោក កែវ មាស ហ្នឹងឯងគឺ គាត់មានឈ្មោះហៅក្រៅជាអាចារ្យ កង ។ នេះគឺជាការប្រកបឈ្មោះ កែវ មាស និងឈ្មោះអាចារ្យ កង ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ឥឡូវដោះស្រាយបញ្ហាលោកមេធាវី ហ្វ្រង់ស្វ័រ រូ លើកឡើងអំមិញហ្នឹងពីរឈ្មោះហ្នឹង តើយើងអាចធ្វើបានទេទាំងឈ្មោះអក្សរខ្មែរ ហើយអក្សរឡាតាំង ហើយក្រឡាបញ្ជីសរសេរហ្នឹងយកទៅបញ្ចាំងនៅខាងណាបាន? អាចធ្វើបានទេ អ្នកបច្ចេកទេសខាងកុំព្យូទ័រនេះ?

[១៣:៥៦:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំយល់ថា មានបញ្ហាបច្ចេកទេស ។ ក្រឡាបញ្ជីម្នាក់នៅពេល មានន័យថាគាត់មិនអាចសរសេរបានអក្សរជាភាសាបារាំងអង់គ្លេស ឬក៏ជាភាសាខ្មែរនៅពេលដំណាលគ្នានោះទេ ។ ខ្ញុំជឿថានេះជាបញ្ហាបច្ចេកទេស ហើយអាចពិបាកណាស់នៅក្នុងការបង្ហាញនូវអក្សរជាពីរភាសានៅក្នុងពេលដំណាលគ្នានោះ ។

[១៣:៥៩:៥៦]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! ប្រហែលជាយើងអាចស្នើខាងផ្នែកសោតទស្សន៍ហ្នឹងឲ្យរៀបចំកម្មវិធីហ្នឹងសម្រាប់សប្តាហ៍ក្រោយ ។ ហើយបើសិនជាមិនអាចធ្វើបាននៅក្នុងពេលនេះ ពីព្រោះអីមើលទៅសម្រាប់ ខ្ញុំៗយល់ថាមិនមែនជាបញ្ហាលំបាកស្មុគស្មាញពេកទេ ខាងផ្នែកបច្ចេកទេសនោះ ។

**ប្រធានអង្គជំនុំ៖**

លោកនិយាយថា អត់ស្មុគស្មាញ ប៉ុនឥឡូវអ្នកបច្ចេកទេសធ្វើអត់កើតផង អ៊ីចឹងវាអាចផ្ទុយជាមួយគំនិតរបស់លោក ព្រោះលោកមិនអាចជ្រៅជ្រះទៅដល់កិច្ចការជំនាញផ្សេងទៀតបានទេ ។ នោះជាការប៉ាន់ស្មានប៉ុណ្ណោះ ។ ឥឡូវ ខាងបច្ចេកទេសអាចសម្រាកបញ្ឈប់ការងារសាកល្បងប៉ុណ្ណឹងសិន ហើយអាចរៀបចំនៅក្នុងសប្តាហ៍ សម្រាប់សប្តាហ៍ក្រោយដើម្បីកុំឲ្យមានការយឺតយ៉ាវព្រោះយើងបានយឺតសវនាការហ្នឹងជាច្រើនហើយ ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្ត ។

**សួរដោយ លោក តាន់ សេណារ៉ុង៖**

**ស៖** អរគុណលោកប្រធានអង្គជំនុំជម្រះ ហើយក៏សូមថ្លែងអំណរគុណផងដែរ ដល់បណ្ឌិតអេតឆេសាន់ ដែលបានចំណាយពេលវេលាអស់រយៈពេលសាមសិបឆ្នាំក្នុងការស្រាវជ្រាវនូវប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជារហូតបានលទ្ធផលមកដល់ថ្ងៃនេះ ដែលជាផលប្រយោជន៍ដ៏ធំសម្រាប់ការិយាល័យ

សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះទាំងមូល ហើយជាពិសេសទៅទៀតសម្រាប់ដល់ប្រជាជនខ្មែរដែលពុំមានការយល់ដឹងដល់ប្រវត្តិសាស្ត្រនូវប្រវត្តិសាស្ត្រដែលនិយាយលម្អិតអំពីបក្សកុម្មុយនីស្តកម្ពុជាដែលមានរបបខ្មែរក្រហមនៅក្នុងនុំងដែរនោះ ។

ដូច្នេះ សំណួរតាមការស្រាវជ្រាវរបស់លោកអស់រយៈពេលដ៏ច្រើនឆ្នាំហ្នឹង ខ្ញុំចង់សួរលោក ហើយសូមលោកនិយាយមិនបាច់លម្អិតពេកទេ ក្នុងការស្រាវជ្រាវកន្លងមករបស់លោក ថាតើបក្សកុម្មុយនីស្តកម្ពុជាចាប់តាំងពីពេលកកើតមកហ្នឹង បានបើកសន្និបាតជាតិហ្នឹង បានប៉ុន្មានលើក? ចាប់តាំងពីថ្ងៃកកើតរហូតមកដល់ថ្ងៃដួលរលំហ្នឹង? ហើយក្នុងការបើកសមាជនីមួយៗហ្នឹង ថាតើសមាជជាតិដែលហៅថា សន្និបាតរបស់បក្សកុម្មុយនីស្តកម្ពុជានុំង មានដែលបានអនុម័តនូវលក្ខខណ្ឌអ្វីសំខាន់ៗដែលជាប្រយោជន៍របស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងទៀតទេ? ទីពីរ ។ ហើយទីបី សំណួរសួរថា តើនៅពេលប្រជុំសន្និបាតគេហៅសមាជជាតិនុំង ពីដំបូងសមាជិកមជ្ឈិមបក្ស សមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាមានអ្នកណាខ្លះចូលរួម? ហើយបើសិនជានៅពេលនោះមិនមែនជាឈ្មោះបក្សកុម្មុយនីស្តកម្ពុជាទេនោះ សូមលោកពន្យល់ដល់តុលាការផង ថាតើឈ្មោះអ្វី? នៅពេលដែលចាប់ផ្តើមកកើតបក្សកុម្មុយនីស្តកម្ពុជានុំង សមាជិកនីមួយៗ ហើយរាល់ពេលប្រជុំបន្តៗបន្ទាប់មកទៀតនោះ ថាតើមានការផ្លាស់ប្តូរសមាជិកនោះដែរឬទេ? ហើយនៅឆ្នាំចុងក្រោយហ្នឹងគឺការប្រជុំសមាជជាតិហ្នឹងនៅឆ្នាំណា? ហើយបានអនុម័តអ្វីខ្លះ?

**ឆ៖** សូមអរគុណលោកសហព្រះរាជអាជ្ញា ។ នៅចន្លោះរវាងការបង្កើតបក្ស និងចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យមានការប្រជុំសមាជជាទូទៅរបស់បក្សចំនួនប្រាំ គឺនៅក្នុងឆ្នាំ(១៩)៦០ ឆ្នាំ៦៣ ឆ្នាំ៧១ ឆ្នាំ៧៦ និងឆ្នាំ៧៨ ។ នៅក្នុងឆ្នាំ៦០ មានអ្នកចូលរួមប្រហែលជាម្ភៃនាក់ ហើយពេលនោះគឺថាបានបង្កើតអង្គការមួយ គេហៅថា “អង្គការពលករកម្ពុជា” ។

ពួកគេបានជ្រើសរើសសមាជិកមជ្ឈិមពីប្រាំបីទៅដប់នាក់ ហើយពីសមាជិកអចិន្ត្រៃយ៍នោះ គេបានជ្រើសរើស លោក ទូ សាមុត ជាលេខារបស់បក្ស ហើយនិង នួន ជា ជាអនុលេខា ។ ពួកគេក៏បានបង្កើតនូវកម្មវិធីនយោបាយផងដែរ ។ នៅក្នុងសមាជឆ្នាំ១៩៦៣ លោកលេខា សាមុត ត្រូវបានគេធ្វើឃាត ពេលនុំងបក្សបានជ្រើសរើស សាឡុត ស ដែលក្រោយមកគាត់ត្រូវបានគេស្គាល់ថា ជា ប៉ុល ពត ក្លាយទៅជាលេខាថ្មី ។ ចំណែក នួន ជា នៅជាអនុលេខាបក្សដដែល ។ ហើយសមាជិកបន្ថែមទៀតត្រូវបានបន្ថែមទៅក្នុងគណៈមជ្ឈិមនិងនៅក្នុងគណៈអចិន្ត្រៃយ៍ ។

នៅក្នុងឆ្នាំ១៩៧១ នៅពេលដែលសមាជិក នៅពេលដែលបក្សបានធ្វើសមាជលើកទី៣របស់ខ្លួន ពួកគេបានសម្រេចចិត្តប្តូរឈ្មោះបក្សឱ្យទៅជាបក្សកុម្មុយនីស្តកម្ពុជាវិញ ហើយពួកគេក៏បានចូលរួមនៅក្នុងការធ្វើផែនការជាច្រើនសម្រាប់សង្គ្រាមក្នុងការរំដោះប្រទេសជាតិ ។ នៅពេលដែលពួកគេធ្វើសមាជជាតិលើកទី៤ នៅឆ្នាំ១៩៧៦ បក្សបានត្រួតត្រាប្រទេសទាំងស្រុង ហើយបានរៀបចំធ្វើឱ្យអភិវឌ្ឍន៍ទៅមុខនូវផែនការរបស់ខ្លួន ដើម្បីគ្រប់គ្រងអំណាចរដ្ឋ និងអំណាចផ្តាច់ការវណ្ណៈអធនរបស់ខ្លួន ហើយបានអភិវឌ្ឍន៍ទៅមុខនៅក្នុងផែនការរបស់ខ្លួនសម្រាប់ការកែប្រែទ្រង់ទ្រាយធំទៅលើសង្គមប្រទេសខ្មែរ ។

នៅក្នុងសមាជឆ្នាំ៧៦នោះ ពួកគេបានអនុម័តនូវលក្ខន្តិកៈថ្មីមួយសម្រាប់បក្សកុម្មុយនីស្តកម្ពុជា ហើយលក្ខន្តិកៈនុ៎ងឯង គឺមានបញ្ចូលនៅក្នុងសំណុំរឿង នៅក្នុងចំពោះមុខអង្គសវនាការយើងនេះ ។ នៅក្នុងសមាជលើកទី៥របស់ខ្លួនក្នុងឆ្នាំ១៩៧៨ មានគោលការណ៍មួយចំនួន និងសកម្មភាពមួយចំនួននៃសមាជនោះ គឺដើម្បីធ្វើការជ្រើសតាំង តែងតាំងលេខាតំបន់ភូមិភាគថ្មី ដើម្បីជំនួសឱ្យលេខាភូមិភាគចាស់ៗដែលត្រូវបានបោសសម្អាតនៅក្នុងដំណាក់កាលនៃការបោសសម្អាត ដែលបានធ្វើឡើងជាបន្តបន្ទាប់ក្នុងរយៈពេលពីរឆ្នាំមុននេះ ។ តើព័ត៌មានដែលខ្ញុំបានលើកឡើងនេះ ឆ្លើយតបទៅនឹងសំណួររបស់លោកទេ លោកសហព្រះរាជអាជ្ញា?

**ស៖** បាទ, អរគុណ ។ លោកបានឆ្លើយនូវចំណុចសំខាន់ៗ នូវអ្វីដែលខ្ញុំចង់បានហ្នឹងហើយជូនអង្គសវនាការ ប៉ុន្តែតំណាងសហព្រះរាជអាជ្ញា សុំបញ្ជាក់ សួរបញ្ជាក់លោកបន្តិចថា តើអៀង ធីរិទ្ធ ហើយនិង ខៀវ សំផន តើគាត់បានចូលជាសមាជិកពេញសិទ្ធិរបស់មជ្ឈិមបក្សហ្នឹង នៅក្នុងសមាជណាមួយដែរ? តាមការស្រាវជ្រាវរបស់លោក?

[១៤:០៨:៥៧]

**ឆ៖** ទៅតាមការយល់ដឹងរបស់ខ្ញុំ លោកសហព្រះរាជអាជ្ញា គឺថា ខៀវ សំផន បានក្លាយជាសមាជិកពេញសិទ្ធិរបស់គណៈមជ្ឈិមនៅក្នុងសមាជឆ្នាំ៧១របស់បក្ស ។ ប៉ុន្តែ អំពីលក្ខណៈរបស់ អៀង ធីរិទ្ធវិញ គឺថា ខ្ញុំមិនបានដឹងច្បាស់លាស់ទេ ។

**ស៖** បាទ, អរគុណ ។ លោកបានឆ្លើយនូវអ្វីដែលខ្ញុំចង់បានហើយ ។ សំណួរបន្តទៀត ចំពោះលោកនូវអ្វីដែលលោកបានស្រាវជ្រាវនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ដែលផ្តោតទៅលើមាត្រា១០ ។ នៅក្នុងមាត្រា១០ នេះ ដែលវាឋិតនៅក្នុងជំពូកទី៧ ស្តីពីប្រព័ន្ធតុលាការ ការិយាល័យសហព្រះរាជអាជ្ញា គ្រាន់ចង់ឱ្យលោកបញ្ជាក់គ្រួសៗនូវអ្វីដែលលោកបានស្រាវជ្រាវនុ៎ងថា តើនៅក្នុង

មាត្រា១០ របស់រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង ដែលមានចែងអំពីសកម្មភាពប្រឆាំងបំផ្លិចបំផ្លាញ មានលក្ខណៈជាខ្សែសង្វាក់ដែលគ្រោះថ្នាក់ដល់រដ្ឋ ទីមួយ ។ ទីពីរ ចំពោះប្រភេទបទល្មើសក្រៅពីប្រភេទខាងលើនុ៎ង នៅក្នុងត្រេពីរហ្នឹង ថាត្រូវអប់រំកសាងក្នុងក្របខ័ណ្ឌរដ្ឋ ឬក្នុងក្របខ័ណ្ឌអង្គការប្រជាជន ។ ដូច្នេះ សំណួរចង់បានថា តាមការស្រាជ្រាវរបស់លោកហ្នឹង ថាតើពិតមែនតែរដ្ឋធម្មនុញ្ញហ្នឹងគឺជាឡប់ឡែដូចជនជាប់ចោទធ្លាប់បានអះអាង ប៉ុន្តែ ផ្អែកទៅលើការស្រាវជ្រាវរបស់លោកវិញ ថាតើលោកមានការយល់ដឹងនូវចំណុចទាំងពីរដែលខ្ញុំបានសួរលោកហ្នឹង ថាតើសកម្មភាពប្រឆាំងហ្នឹង គេចាត់ថ្នាក់របៀបម៉េច ចំពោះប្រភេទបទល្មើសដែលត្រូវអប់រំកសាងនៅក្នុងក្របខ័ណ្ឌរដ្ឋហ្នឹងវាចូលក្នុងផ្នែកណា ដែលតាមការយល់ដឹង ដែលលោកជាអ្នកស្រាវជ្រាវដ៏មានសារសំខាន់ហ្នឹង?

អរគុណលោក ។

**ឆៈ** លោកសហព្រះរាជអាជ្ញា, មាត្រា១០ នៃរដ្ឋធម្មនុញ្ញរបស់បក្សរបស់កម្ពុជាប្រជាធិបតេយ្យបានចែងថា ចំពោះប្រភេទសកម្មភាពប្រឆាំងដែលផ្ទុយទៅនឹងអង្គការប្រជាជន នឹងត្រូវដាក់ទារុណកម្មដោយកម្រិតខ្ពស់ ទោះបីជាមិនមានចំណុចជាក់លាក់ច្បាស់លាស់ក៏ដោយ គឺនៅពេលដែលគេនិយាយអំពីការផ្តន្ទាទោសកម្រិតខ្ពស់បំផុតនោះ គឺមានន័យថា ការផ្តន្ទាទោសដល់ជីវិត ។ ហើយជាការពិតណាស់ បទល្មើសជាច្រើនប្រភេទដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាត់ទុកថា ជាបទល្មើសដែលនឹងត្រូវទទួលការផ្តន្ទាជីវិត ។ ជាសកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ដូចដែលជាឃ្លាដែលត្រូវបានលើកឡើង ក្នុងន័យដ៏ទូលំទូលាយបែបនេះ អាចរួមបញ្ចូលទាំងការខកខានមិនបានទៅធ្វើការដោយសស្រាក់សស្រាំ ឬក៏ធ្វើការដោយប្រឹងប្រែងពីដប់ពីរទៅដប់បួនម៉ោងប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍នោះ ។ នេះអាចចាត់ទុកថា ជាការប្រឆាំងទៅនឹងរដ្ឋរបស់ប្រជាជន ។

មាត្រា១០នៃរដ្ឋធម្មនុញ្ញបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ក៏បានចែងទៀតផងដែរថា ចំពោះប្រភេទក្រៅពីប្រភេទខាងលើ ត្រូវអប់រំកសាងក្នុងក្របខ័ណ្ឌអង្គការរដ្ឋ ឬក្នុងក្របខ័ណ្ឌអង្គការប្រជាជន ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បន្ថែមពីលើបណ្តាញសន្តិសុខទូទាំងប្រទេស ដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងក្នុងការសួរចម្លើយ ធ្វើទារុណកម្ម និងធ្វើការប្រហារជីវិតនោះ គឺនៅមានបណ្តាញមួយទៀត ដែលជាស្ថាប័នមួយដែលត្រូវបានគេស្គាល់ថា ជាបណ្តាញអប់រំ កសាងអប់រំ ។ ជាការពិតណាស់ អ្វីដែលស្ថាប័ននោះ គឺជាជំរំបង្ខំឲ្យធ្វើការជាទម្ងន់ ។

[១៤:១៤:៣៧]

ចំណុចជាច្រើន យើងអាចមើលឃើញថា នៅក្នុងរដ្ឋកម្ពុជាប្រជាធិបតេយ្យនោះ គឺមានជំរំបង្ខំឲ្យធ្វើការដល់ទម្ងន់ មានជាច្រើនណាស់សម្រាប់ប្រជាជនទាំងអស់នៅក្នុងទូទាំងប្រទេស ។ យ៉ាងណាក៏ដោយ នៅពេលដែលជនណាម្នាក់បានប្រព្រឹត្តនៅអ្វីដែលជាចាត់ទុកថា ជាកំហុស ឬក៏បទល្មើសស្រាល ពួកគេនឹងត្រូវបានបញ្ជូនទៅជំរំអប់រំកសាងនេះ ដោយត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់ ហើយនិងឲ្យហូបម្ហូបអាហារដែលមានចំនួនមិនគ្រប់គ្រាន់ មានន័យថាពួកគេរងភាពវេទនាជាងប្រជាជនទូទៅ ។ ស្ថានភាពនៅក្នុងបណ្តាញនៃការអប់រំកសាងនេះ គឺមានលក្ខណៈអមនុស្សធម៌ខ្លាំងណាស់ ហើយជាទូទៅគឺថាមានចំនួនអ្នកស្លាប់ដ៏ច្រើន ក្នុងចំណោមអ្នកដែលត្រូវបានគេបញ្ជូនទៅជំរំអប់រំកសាងនោះ ។ បើសិនជាយើងពិនិត្យតាម ពិនិត្យមើលនូវសាខាមន្ទីរស-២៤ ដែលជាផ្នែកមួយនៃស-២១ នោះគឺថា យើងឃើញថា មានមនុស្សបីប្រភេទនៅក្នុងមន្ទីរអប់រំនេះគឺ អ្នកទោសស្រាល អ្នកទោសមធ្យម និងអ្នកទោសធ្ងន់ធ្ងរ ។

អ្នកទោសស្រាល ប្រសិនបើពួកគេធ្វើការខ្លាំង មានអត្តចរិតល្អ ហើយនិងអាចទ្រាំទ្របាននូវស្ថានភាពអមនុស្សនោះ អាចនឹងត្រូវបានគេដោះលែងឲ្យទៅរស់នៅតាមសហករណ៍ ឬតាមស្ថាប័នរបស់ខ្លួនវិញ ។ សម្រាប់អ្នកប្រព្រឹត្តបទល្មើសធ្ងន់ជាទូទៅ គឺត្រូវធ្វើការរហូតដល់ខ្លួនស្លាប់ ឬក៏ត្រូវបានគេសម្លាប់ភ្លាមតែម្តង ។ សម្រាប់អ្នកដែលមានទោសមធ្យមនោះ ឬក៏អ្នកដែលត្រូវបានគេវាយតម្លៃថាតើពួកគេហ្នឹងគួរតែត្រូវដាក់នៅក្នុងក្រុមអ្នកទោសស្រាល ឬក៏អ្នកទោសធ្ងន់នោះ? ពីព្រោះមិនមានបណ្តាញឬក៏គម្រោងនៃប្រព័ន្ធច្បាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយពីព្រោះគោលនយោបាយត្រូវបានប្រកាសឡើងដោយថ្នាក់លើនៃអង្គការចាត់តាំង គឺមានការអភិវឌ្ឍន៍ជាបន្តបន្ទាប់និងជាញឹកញាប់ ។ ដូច្នេះ ប្រជាជនមិនអាចបានដឹងថា តើអ្វីទៅដែលជាច្បាប់នោះ? ហើយតើអ្វីទៅដែលជាការជំទាស់ទៅនឹងរដ្ឋរបស់ប្រជាជន? ឬក៏តើអ្វីទៅគឺជាបទល្មើសដែលបណ្តាលឲ្យគេត្រូវបានឃុំឃាំងខ្លួននោះ និងត្រូវបានគេបញ្ជូនទៅមន្ទីរអប់រំកសាង ឬក៏មន្ទីរសន្តិសុខនោះ?

ចំណុចនេះគឺថា រដ្ឋកម្ពុជាប្រជាធិបតេយ្យ គឺជារដ្ឋមួយដែលធ្វើអ្វីតាមទំនើងចិត្តរបស់ខ្លួន ។

[១៤:១៨:១២]

**ស៖** អរគុណ បណ្ឌិត អេតឆេសាន់ ។ ចំណុចត្រួសៗ ដែលលោកបានរៀបរាប់ហ្នឹង ធ្វើឲ្យអង្គសវនាការ ជាពិសេសតំណាងសហព្រះរាជអាជ្ញាហ្នឹង បានយល់ដឹងហើយ។

សំណួរបន្តទៀតចំពោះបណ្ឌិត ដែលបានស្រាវជ្រាវអស់រយៈពេលដ៏យូរហ្នឹង សួរថាតើលោក

អាចអធិប្បាយអំពីតួនាទីពិតប្រាកដ និងសារសំខាន់របស់សភាប្រជាជនហ្នឹងបានទេ? មិនបាច់លម្អិតពេកទេ សូមឲ្យលោកនិយាយត្រួសៗ គោលៗបានហើយ ចង់បានតែគោលៗ សំខាន់ៗ ដើម្បីឲ្យអង្គសវនាការហ្នឹង បានយល់បានហើយ ។ អធិប្បាយត្រួសៗ បាទ, អរគុណ ។

**ឌុះ** បាទ, លោកសហព្រះរាជអាជ្ញា ។ តាមទ្រឹស្តីសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ គឺត្រូវបានតែងតាំងក្នុងរយៈពេលប្រាំឆ្នាំម្តង ដោយធ្វើការបោះឆ្នោតដោយផ្ទាល់ ធ្វើការបោះឆ្នោតដោយសម្ងាត់ នេះគឺយោងតាមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ សភាអ្នកតំណាងសភាទាំង ២៥០ ត្រូវបានតែងតាំងដោយថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជា ។ សភាតំណាងប្រជាជន គឺវាខុសពីអង្គនីតិបញ្ញត្តិផ្សេងៗទៀតនៅក្នុងប្រទេសដទៃ ដែលមិនជួបប្រជុំជាញឹកញាប់នោះទេ ហើយមិនបានធ្វើការអនុម័តច្បាប់ ហើយក៏មិនមានភារកិច្ចទាល់តែសោះក្រៅពីបម្រើជាការឃោសនា ដើម្បីធ្វើយ៉ាងណាបង្កើតឲ្យមានកេរ្តិ៍ឈ្មោះដល់កម្ពុជាប្រជាធិបតេយ្យនៅក្នុងពិភពលោក ។

នៅក្នុងឯកសារមួយដែលមាននៅក្នុងសំណុំរឿង គឺកិច្ចកំណត់ប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ដែលមានលេខ ERN00017116 ដល់លេខ ខ្ញុំគិតវាមានកំហុសនៅក្នុងលេខ ERN នេះ ។ ដោយសារតែលេខ ERN នៅតួចុងក្រោយវាមានលេខទាបជាងលេខខាងមុខ ដូច្នេះ គឺខ្ញុំមានលេខ 000171 គឺខ្ញុំ លេខចុងក្រោយ គឺខ្ញុំអត់មានទេ ដោយសារវាមានកំហុសនៅត្រង់ចុងក្រោយនេះ ។

**ប្រធានអង្គជំនុំ៖**

ចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

គឺនៅក្នុងលេខ៥៥ នៃបញ្ជីរបស់សហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

គឺលេខ៥៦ លោកចៅក្រមជាទីគោរព ។

យើងក៏មានលេខ ERN បារាំងផងដែរ អត់មាននៅក្នុងឯកសាររបស់លោក អេតឆេសាន់ គឺលេខ 00323932 រហូតដល់លេខ 00323936 ។ ខ្ញុំក៏អាចផ្តល់លេខ ERN ជាភាសាអង់គ្លេសផងដែរ គឺលេខ 00182628 ដល់លេខ 00182634 ។

**លោក ហ្វេង់ស្វ័រ រូ៖**

លោកប្រធានអាច ថាតើលេខជើងទំព័រ គឺ *ហ្វូតណូត* អាចផ្តល់ផងដែរឬទេដែលលេខជើងទំព័រនេះវាអាចជាផលប្រយោជន៍សម្រាប់យើងខ្ញុំ ។

ប្រហែលលោក អេតឆេសាន់ មានលេខជើងទំព័រ គឺ *ហ្វូតណូត* នេះ ។

**ប្រធានអង្គជំនុំ៖**

លោកបណ្ឌិតអាចផ្តល់លេខ *ហ្វូតណូត* ហ្នឹង បានទេ?

**លោក ក្រេក អេតឆេសាន់៖**

អាចបានលោកប្រធាន ។ សូមអរគុណលោកចៅក្រម ឡាវែន៍ ហើយនិងសហព្រះរាជអាជ្ញាដែលប្តឹងផ្តល់លេខ ERN នេះ ។ លេខជើងទំព័រ *ហ្វូតណូត* នៅក្នុងរបាយការណ៍ទាក់ទងទៅនឹងទស្សនៈទាននៃឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ គឺមានលេខជើងទំព័រ ៣៥៥ ។

បើសិនជាយើងត្រឡប់ទៅសំណួររបស់ខាងសហព្រះរាជអាជ្ញាវិញ កិច្ចប្រជុំមួយរបស់គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា គឺវាជាការរៀបចំក្នុងបោះឆ្នោតសភាតំណាងប្រជាជន ។ ហើយនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះ គឺយើងឃើញមានយោបល់ ខ្ញុំសូមដកស្រង់ "ប្រសិនបើបុគ្គលណាមួយសួរថា មិនឲ្យនិយាយជាក់លាក់នៅចំពោះមុខប្រជាជន ដើម្បីកុំឲ្យគេមានការថតចាប់យកព័ត៌មានអីផ្សេងៗ" សូមបញ្ចប់ ។ ហើយចំពោះខ្ញុំវាជាការខកខានរបស់គណៈអចិន្ត្រៃយ៍ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រសិនបើខ្ញុំអាចស្នើសុំបាន អ្នកបកប្រែបារាំង គឺហាក់ដូចជាមិនយល់នូវការដកស្រង់នូវសម្តីរបស់លោកសូមឲ្យលោកអានឲ្យបានយឺតបន្តិចទៅលើករណីនេះ ។

**លោក ក្រេក អេតឆេសាន់៖**

បាទ, ខ្ញុំអាចធ្វើទៅបាន គឺខ្ញុំសូមដកស្រង់ម្តងទៀត "បើមានគេសួរ យើងត្រូវពន្យល់កុំច្រងេងច្រងាងកុំឲ្យឃើញថា យើងចង់បង្ក្រាប" ខ្ញុំសូមបិទនូវសម្តីដកស្រង់វិញ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** សូមត្រឡប់មកសួរបណ្ឌិតអេតឆេសាន់ជាថ្មីឡើងវិញ ។ ឯកសារបន្ទាប់ គឺនឹងនិយាយអំពីគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលនៅពេលនេះវាទាក់ទិនឹងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាហ្នឹងឯង ។ សំណួរសួរថា តើសូមលោកអធិប្បាយខ្លីៗបាន ថាតើលក្ខន្តិកៈនេះអនុវត្តចំពោះនរណាខ្លះ

តាមការស្រាវជ្រាវរបស់លោកកន្លងមក?

[១៤:២៨:៤០]

**ឆ៖** សូមអរគុណលោកសហព្រះរាជអាជ្ញា ។

លក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា គឺមានន័យថា សម្រាប់សមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាទាំងអស់ត្រូវអនុវត្ត ។ ក៏ប៉ុន្តែ ដោយសារថា លក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា គឺជាឯកសារមគ្គុទេសក៍របស់អង្គការដែលនឹងត្រូវយកមក ដែលជាអង្គការអនុវត្តនូវភាពផ្តាច់ការនៅក្នុងប្រទេសកម្ពុជា ហើយបទប្បញ្ញត្តិភាគច្រើន ដែលមាននៅក្នុងលក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជានោះ គឺដាក់ឡើងសម្រាប់ប្រជាជនទាំងអស់នៅទូទាំងប្រទេស ។

**សៈ** បាទបណ្ឌិតខ្ញុំអាចទទួលយកបានហើយនូវចំណុចខ្លីៗ ដែលលោកបានអធិប្បាយហ្នឹង ។ សំណួរបន្តទៅទៀត នឹងនិយាយអំពីគោលការណ៍គ្រឹះ ។ គោលការណ៍លាក់ការណ៍ (សុំទោស) លាក់ការណ៍និងគោលជំហរនយោបាយជាមូលដ្ឋានរបស់បក្ស ក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម នៅក្នុងហ្នឹងគេមានចំណាត់ការអំពីគោលការណ៍ហ្នឹងវែង ស្តីពីការកសាងសង្គមនិយម និងការការពារបដិវត្តន៍ជាកិច្ចការបន្តបន្ទាប់មកទៀត ។ ក្នុងនោះមានបញ្ជាក់លម្អិតអំពីលទ្ធិម៉ាក្សលេនីន និងទស្សនៈពិភពលោក បក្សពលករនិយមដែលត្រឹមត្រូវនិងខ្លាំងក្លា ។

អ៊ីចឹង នៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តដែលបានដាក់ចេញនូវគោលជំហរជាមូលដ្ឋាន ឬជាទស្សនៈដែលខ្លួនប្រកាន់យកហ្នឹង វាមានរៀបចំនូវគំនិតមួយយ៉ាងវែង ដែលបក្សត្រូវតែប្រឆាំងដាច់ខាតនោះ ។ ក្នុងនោះដែរ ក៏មានការរួមបញ្ចូលក្នុងការប្រឆាំងរបស់ខ្លួនជាពិសេសណាមួយ ទៅនឹងការបំពារបំពាននយោបាយដែលមានទស្សនៈ និងអង្គការវិន័យរបស់បក្សផងដែរ និងអង្គការផងដែរ ។ ហើយលើសពីនោះទៅទៀត ក៏ទាមទារឲ្យបក្សហ្នឹងត្រូវតែមានការប្រុងប្រយ័ត្ន កម្រិតខ្ពស់ចំពោះសកម្មភាពនិងកលល្បិចទាំងអស់របស់សត្រូវដែរ ។ សំណួរចង់សួរបណ្ឌិតដែលជាជំនាញ ដែលបានស្រាវជ្រាវនូវប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសប្រវត្តិសាស្ត្ររបស់ប្រទេសពីដើមមកនោះ ថាតើលោកអាចអធិប្បាយជាលក្ខណៈទូទៅដែលចេញពីឯកទេសរបស់លោកផ្ទាល់តាមការដែលលោកបានអានឯកសារ ថាតើគោលគ្រឹះរបស់បក្សជាក់ស្តែងនោះវាចេញយ៉ាងដូចម្តេច ចំពោះពួកគេ?

**ឆ៖** សូមអរគុណលោកសហព្រះរាជអាជ្ញា ។ គោលការណ៍គ្រឹះសំខាន់មួយដែលបក្សកុម្មុយ-នីស្តកម្ពុជាបានអនុវត្តតាមយ៉ាងតឹងរ៉ឹង ជាពិសេសពីពេលពួកគេបានគ្រប់គ្រងអំណាចមក គឺគោលការណ៍

ដែលគេទទួលស្គាល់ថា គឺម្ចាស់ការឯករាជ្យ ។ គោលការណ៍ម្ចាស់ការឯករាជ្យនេះ គឺមាននិយមន័យផ្តល់អំពីទស្សនៈទានទៅលើផ្នែកនយោបាយនិងសេដ្ឋកិច្ច ដែលមានន័យថា មេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាជឿថា បដិវត្តន៍ គឺមានលក្ខណៈពិសេស ។ ដូច្នេះហើយ មិនចាំបាច់មានការស្វែងរកការណែនាំពីគំរូនៃបក្សកុម្មុយនីស្ត ឬក៏បដិវត្តន៍កុម្មុយនីស្ត ដែលមានពីមុនៗមកនោះទេ ។ ពួកគេជឿជាក់ថា បដិវត្តន៍បក្សកុម្មុយនីស្តពីមុនមកហ្នឹងបានបរាជ័យ ព្រោះតែពួកគេបានខកខានក្នុងបំផ្លាញវណ្ណៈជិះជាន់នៅក្នុងសង្គម គឺពួកសក្តិភូមិ ពួកនាម៉ឺន ហើយនិងពួកសក្តិភូមិ ។ ដូច្នេះ កម្ពុជាប្រជាធិបតេយ្យបានធ្វើបដិវត្តន៍ ហើយបានកំណត់ក្នុងការបំបាត់ចោលនូវវណ្ណៈអស់ទាំងនោះឲ្យខ្ទេចខ្ទីទាំងស្រុងតែម្តង ។ ហើយពួកគេធ្វើដូច្នេះ គឺដើម្បីអាស្រ័យតែទៅលើវណ្ណៈមួយ គឺវណ្ណៈពលករ កសិករ កម្មករ កសិករ ហើយដែលធ្វើការបំបាត់ចោលនូវវណ្ណៈទាំងអស់នៅក្នុងសង្គម ដោយធ្វើការកែប្រែពួកវណ្ណៈនាយទុនអស់ទាំងហ្នឹង ឲ្យក្លាយទៅជាវណ្ណៈកសិករ ។ ដូច្នេះហើយ ពួកគេនឹងអាចទទួលបាននូវសង្គមមួយដែលគ្មានឋានៈទាំងអស់ដែលគ្មានវណ្ណៈទាំងអស់ ហើយដែលបានធ្វើឡើងនៅពេលដំណាលៗគ្នា ដើម្បីសម្រេចបាននូវបក្សកុម្មុយនីស្តដ៏បរិសុទ្ធមួយ ។

ទស្សនទាននៃការធ្វើកំណែទម្រង់សង្គមបែបនេះ គឺមិនបានយកមកពិចារណា នូវប្រវត្តិនៃការកសាងទ្រឹស្តីបក្សកុម្មុយនីស្តពីមុនមកនោះទេ ។ ដោយមិនយោងទៅលើទស្សនៈនៃទ្រឹស្តីម៉ាក្ស លេនីន ឬពី ម៉ាក្ស រហូតដល់ លេនីន ឬក៏រហូតដល់ ស្តាលីន ឬក៏លទ្ធិកុម្មុយនីស្តរបស់ ម៉ៅ ឬក៏អ្នកដែលជាអ្នកផ្តើមគំនិតនៃបក្សកុម្មុយនីស្តដទៃទៀត ។ ក៏ប៉ុន្តែ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជឿថា តាមរយៈទស្សនទានបែបនេះ មានន័យថា ទស្សនៈនៃការធ្វើម្ចាស់ការឯករាជ្យ ដោយខ្លួនឯងជាអ្នកកំណត់នូវវាសនារបស់ខ្លួនឯងតាមរយៈទម្រង់នៃទំនាក់ទំនងរវាងសេដ្ឋកិច្ចនិងនយោបាយជាមួយពិភពខាងក្រៅ គឺពួកគេនឹងអាចទទួលបាននូវបដិវត្តន៍ដ៏មានលក្ខណៈពិសេសមួយ ហើយនឹងក្លាយទៅជាគំរូនៃបដិវត្តន៍សម្រាប់ពិភពលោកទាំងមូល ។

តើនេះជាអ្វីដែលឆ្លើយតបទៅនឹងសំណួររបស់លោកទេ លោកសហព្រះរាជអាជ្ញា?

**ស៖** បាទ, អរគុណបណ្ឌិត អេតឆេសាន់ ។ តំណាងសហព្រះរាជអាជ្ញាចង់បានគំនិតគោលៗប៉ុណ្ណឹងបានហើយ ។ សំណួរបន្តទៀតទៅជូនបណ្ឌិត គឺមានដូចខាងក្រោម៖

នៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង លោកដឹងស្រាប់ហើយថា អង្គការបក្សទាំងអស់ និងគ្រប់សមាជិករបស់បក្សទាំងអស់នោះ ត្រូវតែល្អ ស្អាតស្អំ និងបរិសុទ្ធ ផ្នែកនយោបាយក្តី

មនោគមវិជ្ជាក្ដី និងអង្គការ ហើយអង្គការនោះដោយបានកសាងឲ្យបាននូវប្រវត្តិផ្ទាល់របស់ខ្លួនឲ្យបានច្បាស់លាស់ ស្អាតស្អំ ហើយបរិសុទ្ធទៀតផង ។ នៅក្នុងនោះដែរ វាមានការទិតៀន ស្វ័យទិតៀនដែលជាទម្លាប់ប្រចាំថ្ងៃ ហើយនោះដែលគេមានន័យថា ត្រូវតែកសាងផ្ទៃក្នុងរបស់បក្ស ។

សំណួរចង់សួរបណ្ឌិតដែលជាអ្នកជំនាញហ្នឹង ដើម្បីឲ្យយោបល់ត្រួសៗ អំពីការពិនិត្យ ឯកសារផ្ទាល់ ហើយនិងឯកសារដទៃទៀត ដែលបណ្ឌិតបានស្រាវជ្រាវហ្នឹងថា តើគោលការណ៍នេះវាត្រឹមត្រូវ វាល្អ បរិសុទ្ធ ដើម្បីអនុវត្តហ្នឹងទូទាំងប្រទេសកម្ពុជាដែរមែនទេ?

[១៤:៣៨:០៩]

**ឆ៖** សូមអរគុណលោកសហព្រះរាជអាជ្ញា ។ មាត្រា១ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា បាននិយាយអំពីលក្ខណៈវិនិច្ឆ័យ ក្នុងការចូលបម្រើជាសមាជិកបក្ស ។

នៅមាត្រា១(គ) មានចែងថា គឺត្រូវតែស្អាតស្អំ ទាំងជីវភាព ទាំងនយោបាយ ហើយមិនមានពាក់ព័ន្ធជាមួយនឹងខ្មាំង ។ ចំណុចនេះ គឺទាក់ទងទៅនឹងទស្សនៈទានដែលថា ខ្មែរក្រហម ហៅថា ភាពបរិសុទ្ធ ភាពស្អាតស្អំ ឬក៏ថា មានភាពស្អាតស្អំ ។ ប្រហែលជាខ្ញុំអាចបង្ហាញបាន អំពីទស្សនទាននេះដោយលើកឡើងជាឧទាហរណ៍ ទាក់ទងទៅនឹងស-២១ ។

នៅប៉ែកខាងកើតកំពង់ឆ្នាំង មានស្រុកមួយឈ្មោះថា កំពង់ត្រឡាច ដែលនៅអបនឹងទន្លេសាបតាមលក្ខណៈប្រវត្តិសាស្ត្រ ហើយនៅពេលបច្ចុប្បន្ននេះក៏ដោយ ប្រសិនបើខ្ញុំមិនច្រឡំទេនោះ កំពង់ត្រឡាចនេះ ស្រុកកំពង់ត្រឡាច គឺជាតំបន់មួយដែលមានភាពក្រីក្រជាងគេ នៅក្នុងប៉ែកកណ្ដាលនៃប្រទេសកម្ពុជា ហើយមានប្រជាជនក្រីក្រជាច្រើនណាស់ដែលរស់នៅទីនោះ ។ ឌុច បានជ្រើសរើសក្មេងប្រុសៗជាច្រើនមកពីកំពង់ត្រឡាចនោះ ដើម្បីជ្រើសរើសក្លាយទៅជាបុគ្គលិកធ្វើការនៅស-២១ ។ ទៅតាមការយល់របស់ខ្ញុំនោះគឺថា អ្វីដែលគាត់ធ្វើពីព្រោះពួកគេមកពីតំបន់មួយដែលជាកសិករក្រីក្រជាងគេ ជាវណ្ណៈមួយ ដែលបដិវត្តន៍ខ្មែរក្រហមនោះឯងពេញចិត្ត ។ ហើយដោយសារពួកគេ មកពីតំបន់ដាច់ស្រយាល ហើយក្រីក្រផង ពួកគេហ្នឹងគឺថាមិនមានទទួលឥទ្ធិពលពីបរទេស ឬក៏ពីឥទ្ធិពលអ្នកដែលរស់នៅទីក្រុង ឬក៏ពីអ្នកនាយទុន ឬក៏សក្តិភូមិនោះទេ ។ មានន័យថាពួកគេ គឺមានប្រវត្តិស្អាតស្អំ ហើយដោយសារពួកគេជាក្មេងៗ ដូចដែលជនជាប់ចោទបាននិយាយនៅក្នុងសេចក្ដីថ្លែងការណ៍របស់ខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ពួកគេគឺដូចជាក្រដាសស្អាតសមួយសន្លឹកតែម្ដង ដែលថាយើងអាចសរសេរអ្វីនៅលើក្រដាសនោះក៏បានដែរ ។

ដូច្នេះហើយ នេះគឺជាទស្សទាននៃភាពស្អាតស្អំស្អិតនៅក្រោមខ្មែរក្រហម គឺទាក់ទងទៅនឹងប្រភពនៃវណ្ណៈដើម វណ្ណភាពដើមរបស់បុគ្គលនោះ ។

តើនេះជាអ្វីដែលអាចជាចម្លើយទៅនឹងសំណួររបស់លោកទេ លោកសហព្រះរាជអាជ្ញា?

**ស៖** បាទ អរគុណបណ្ឌិត អេតឆេសាន់ ។ តំណាងសហព្រះរាជអាជ្ញាចង់បានចំណុចត្រួសៗត្រឹមហ្នឹង គឺបាន ទទួលយកបានហើយ ។

សំណួរបន្តទៅទៀតហ្នឹង វាអាចមានការស្នើដល់ជនជាប់ចោទនៅក្នុង ការសួរបញ្ជាក់ ប៉ុន្តែខ្ញុំអាច ដោយនាទីនេះវាមិនមែនជាពេលដែលត្រូវសួរជនជាប់ចោទ បញ្ជាក់នៅលើគោលការណ៍គាំទ្រនូវគោលការណ៍អនុវត្តទាំងនេះ និងស្នើសុំឲ្យជនជាប់ចោទដើម្បីនឹងបញ្ជាក់ថា គោលការណ៍នេះត្រូវបានអនុវត្តនៅមន្ទីរស-២១ ដែរនោះ យើងទុកចាំនៅពេលដែលត្រូវ ដែលជនជាប់ចោទនោះចូលមកឆ្លើយនៅចំពោះមុខអង្គសវនាការចុះ ។ ខ្ញុំនឹងមិនៗអញ្ជើញ សុំអង្គជំនុំជម្រះ ដើម្បីសុំឲ្យជនជាប់ចោទ ដើម្បីមកឆ្លើយបញ្ជាក់ពីគោលការណ៍ទាំងនេះ នៅមន្ទីររបស់គាត់ក្តី និងក្នុងនាមគាត់ជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាទេ ។

ហើយសំណួរបន្តទៀត ខ្ញុំនឹងបន្តទៅដល់បណ្ឌិត នៅកាលពីពីរថ្ងៃមុនហ្នឹង បណ្ឌិតហ្នឹងបានបង្ហាញអង្គជំនុំជម្រះនូវគំនូសតាង ស្តីពីការសម្លាប់ពីកងពល៣១០ មានកងពល៧០៣ និងកងពល៥០២ ក្នុងនោះបណ្ឌិតបានបង្ហាញពីតួលេខនៅក្នុងការចាប់ខ្លួននៅក្នុងឆ្នាំនុំង ដែលមានចំនួនឆ្នាំនិងខែដែលមានឡើង មានតិចនូវភាគរយដែលបណ្ឌិតបានរៀបរាប់ជូនអង្គជំនុំជម្រះ ឃើញថា បណ្ឌិតមានការយល់ដឹងនិងប្រមូលបានព័ត៌មាននោះបានគ្រប់គ្រាន់គួរជាទីទុកចិត្តបាន ។

ហើយសំណួរបន្តនេះ គ្រាន់តែឲ្យបណ្ឌិតមិនបាច់លម្អិតទេ គ្រាន់ថាបើបណ្ឌិតបានដឹងសូមបណ្ឌិតឆ្លើយថាដឹងចុះ មិនចង់ឲ្យបង្ហាញទៅដល់ឯកសារដែលពាក់ព័ន្ធនៅក្នុងសំណួររបស់តំណាងសហព្រះរាជអាជ្ញាហ្នឹងទេ ។

សំណួរសួរថា នៅក្នុងឆ្នាំប្រហែលជា១៩៧៦ បើខ្ញុំមិនច្រឡំទេ ថាតើបណ្ឌិតដែលបានស្រាវជ្រាវនូវព័ត៌មានស្តីពីប្រវត្តិនៃការចាប់ខ្លួនជាឈុតក្តី ដោយឡែកក្តី ថាតើបណ្ឌិតមានបានដឹងថា នៅក្នុងអំឡុងឆ្នាំនុំងមានអាជ្ញាធររបស់ប្រទេសថៃហ្នឹង បានបញ្ជូនជនជាតិខ្មែរមួយចំនួន ខ្ញុំមិនបញ្ជាក់ចំនួនទេ ចាំខ្ញុំនឹងជម្រាបអង្គជំនុំជម្រះនៅពេលក្រោយអំពីចំនួនដែលត្រូវចាប់ខ្លួនពី ដែលបានទទួលយកជនជាតិខ្មែរពីប្រទេសថៃហ្នឹង ។ ថាតើបណ្ឌិតមានបានស្រាវជ្រាវដឹងថា តើនៅកំឡុងឆ្នាំនុំងមានអាជ្ញាធរថៃហ្នឹង

បញ្ជូនជនជាតិខ្មែរដែលបានរត់ទៅចូលដីថៃហើយ ត្រូវបានបញ្ជូនចូលមកតាមព្រំដែន អារញ្ញប្រាថេត ហើយជនជាតិខ្មែរទាំងនុំងត្រូវបានបញ្ជូនយកមកមន្ទីរស-២១ ដែរហ្នឹង ។ ហើយជនជាតិខ្មែរភាគច្រើន ភាគច្រើន នៅក្នុងការដែលចាប់បញ្ជូននោះ ច្រើនតែមកពីភូមិ ខ្ញុំបញ្ជាក់ជូនលោក ប្រហែលជាមកពីខាង ស្រុកសិរីសោភ័ណ ភាគច្រើនគឺភូមិ គេហៅ ភូមិបត់ត្រង់ ដែលបានរត់ចេញពីប្រទេសកម្ពុជាទៅ ថាតើ បណ្ឌិតមានបានស្រាវជ្រាវដឹងពីបញ្ហាបញ្ជូនខ្លួនហ្នឹង មកចូលក្នុងប្រទេសកម្ពុជា ហើយក្រោយមកយក មកក្នុងមន្ទីរស-២១ ទេ?

[១៤:៤៥:៥២]

**ឆ៖** សូមអរគុណសហព្រះរាជអាជ្ញា ។ ខ្ញុំជឿថា មានករណីមួយចំនួនដែលបុគ្គល ឬក៏ក្រុម បុគ្គល ដែលបានរត់គេចពីកម្ពុជាទៅប្រទេសថៃ ត្រូវបានគេបង្ខំឲ្យវិលត្រឡប់មកវិញដោយអាជ្ញាធរ ថៃ ។ ហើយនៅពេលដែលពួកគេត្រូវបានទទួលដោយកម្ពុជាប្រជាធិបតេយ្យនោះ ពួកគេត្រូវបានចាត់ ទុកថា ជាជនក្បត់ ហើយនឹងត្រូវទទួលទណ្ឌកម្ម ដែលមានន័យថា ជាទណ្ឌកម្មដែលគេនឹងដាក់សម្រាប់ ជនក្បត់ជាតិ ។ ខ្ញុំជឿថា មានព្រឹត្តិការណ៍បែបហ្នឹងកើតមាននៅក្នុងឆ្នាំ១៩៧៦ ប៉ុន្តែ ខ្ញុំអត់មានព័ត៌មាន ជាក់លាក់អំពីអ្នកដែលត្រូវបានគេបញ្ជូនមកស-២១ នោះទេ ។ ប្រហែលជានឹងអាចកើតមាន ប៉ុន្តែ ប្រហែល ជាខ្ញុំមិនអាចដឹង ។

**ស៖** អរគុណបណ្ឌិត អេតឆេសាន់ ។ សំណួរដែលពាក់ព័ន្ធដល់ចំណុចនេះ តំណាងសហព្រះ រាជអាជ្ញានឹងសួរលម្អិតនៅពេលណាដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យសួរទៅដល់ជនជាប់ចោទ ដែលវា មានឯកសារពាក់ព័ន្ធនៅក្នុងការបញ្ជូនជនជាតិខ្មែរទាំងអស់នោះចូលសារមន្ទីរទួលស្លែង អ៊ូ! សូមទោស ចូលមន្ទីរសន្តិសុខស-២១ ហើយនិងមានលិខិត លិខិតរបស់អង្គការលើកលែងទោសអន្តរជាតិដែលបាន ផ្ញើមកចូលប្រទេសកម្ពុជា ជូនគណៈប្រធានរដ្ឋ ខៀវ សំផន នៅពេលនោះដែរ ។

សំណួរបន្តទៀតជូនទៅបណ្ឌិត ក្នុងនាមលោកជាអ្នកស្រាវជ្រាវដ៏មានសក្តានុពល នៅក្នុងអង្គ ការិយាល័យសហព្រះរាជអាជ្ញា ជាពិសេសលោកអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រទូទៅហ្នឹង ថាតើលោក អាចពន្យល់បានទេ ថាតើនៅក្នុងមន្ទីរស-២១ វាមានការសម្រិតសម្រាំងកម្មាភិបាល យុទ្ធជន នៅទីនោះ ដែរឬទេ? ពីព្រោះលោកបានបញ្ជាក់ជូនអង្គសវនាការហើយ នៅទូទាំងប្រទេសវាមានការសម្រិតសម្រាំង យុទ្ធជន កម្មាភិបាល ជាដើម ។ សំណួររបស់ខ្ញុំ គឺផ្តោតតែក្នុងមន្ទីរស-២១ ទេ ថាតើក្នុងមន្ទីរស-២១ ហ្នឹងវាមានការសម្រិតសម្រាំង យុទ្ធជន និងកម្មាភិបាល ដូចករណីនៅទូទាំងប្រទេសហ្នឹងដែរឬទេ?

[១៤:៤៩:១៣]

**ឆ៖** សូមអរគុណ លោកសហព្រះរាជអាជ្ញា ។

ជាការពិតគឺមានមែន ដូចអង្គភាព និងអង្គការផ្សេងទៀតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាផងដែរ កម្មាភិបាលនៅស-២១ គឺទាមទារឲ្យធ្វើការប្រជុំជីវភាពបដិវត្តន៍ ដែលនៅពេលនោះមានការទិតៀន និងមានស្វ័យទិតៀន ត្រូវបានធ្វើឡើង ដែលទិតៀននិងស្វ័យទិតៀន នេះគឺជាវិធីសាស្ត្រក្នុងការធ្វើការ បង្កើនសមត្ថភាពរបស់កម្មាភិបាលក្នុងការកសាងបក្ស និងបដិវត្តន៍ ហើយនៅក្នុងករណីមួយចំនួន ការប្រជុំទិតៀន និងស្វ័យទិតៀនអាចមានការប្រជុំទៅលើប្រវត្តិនិងប្រវត្តិការងារផ្សេងៗ ដែលអាចធ្វើការឲ្យមានការលេចចេញនូវជនសង្ស័យណាមួយចេញពីបក្ស ។ ហើយនៅពេលនោះ គឺមានការកំណត់សម្គាល់ឃើញថាមានកម្មាភិបាលជាខ្មាំង ហើយដោយចេញពីមូលហេតុនេះហើយកម្មាភិបាលមួយចំនួនពីស-២១ ត្រូវបានគេចាប់ខ្លួន ហើយបានបញ្ជូនទៅស-២៤ ដើម្បីអប់រំ ។ ហើយជាការពិត កំណត់បញ្ជីរបស់ស-២១ បានបង្ហាញអំពីផ្នែកយ៉ាងធំនៃបុគ្គលិកស-២១ ត្រូវបានក្លាយទៅជាជនរងគ្រោះនៃស-២១ ។

ខ្ញុំខ្លាចថា ខ្ញុំអត់មានតួលេខជាក់លាក់នៅក្នុងថ្ងៃនេះ ប៉ុន្តែ វាមានចំនួនច្រើនណាស់ចំពោះបុគ្គលដែលក្លាយជាជនរងគ្រោះនៅស-២១ នោះ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណ បណ្ឌិត អេតឆេសាន់ ដែលបានបកស្រាយពន្យល់ត្រួសៗនូវវិសុទ្ធកម្ម ដែលមានកើតឡើងនៅមន្ទីរស-២១ ហើយនិងបានឆ្លើយនូវសំណួរដ៏ក្បោះក្បាយនូវអ្វីដែលការិយាល័យសហព្រះរាជអាជ្ញាហ្នឹងចង់បាន ដើម្បីឲ្យបណ្ឌិតដែលជាអ្នកស្រាវជ្រាវហ្នឹងបកស្រាយជូន ។

សូមអរគុណ ហើយខ្ញុំអស់សំណួរ ខ្ញុំនឹងជូននាទីបន្ទាប់ទៀតជូនដល់សហការីរបស់ខ្ញុំ អរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** សូមអរគុណលោកប្រធាន សូមគោរពលោក អេតឆេសាន់ ខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរអំពីតួនាទីរបស់គណៈអចិន្ត្រៃយ៍ ។ លោកបានរៀបរាប់នៅក្នុងទស្សនទានអំពីតួនាទីនៃមន្ទីរ៨៧០ នៅក្នុងរបាយការណ៍របស់លោក លោកបាននិយាយពិស្តារបន្ថែមទៀតអំពីមន្ទីរស-២១ ហើយលោកក៏

បានរៀបរាប់អំពីមន្ទីរដែលមានអក្សរ "ក" ថាតើលោកអាចពន្យល់បន្ថែមចំពោះមន្ទីរស-២១ និងមន្ទីរ "ក" នេះបានដែរឬទេ?

**ឆ៖** សូមអរគុណលោកសហព្រះរាជអាជ្ញា គឺត្រឹមត្រូវហើយ ។ នៅក្នុងមន្ទីរ៨៧០ ឬក៏ក្រោមការគ្រប់គ្រងរបស់មន្ទីរនេះ យើងឃើញមានមន្ទីរ៧១ ដែលយើងអាចយល់ឃើញថា វាជាលេខាធិការដ្ឋាននៃមន្ទីរ៨៧០ ។ យើងឃើញថា មន្ទីរនេះជាមន្ទីរនៃការគាំទ្រទៅដល់មន្ទីរ៨៧០ ដែលវាទាមទារ និងភាពចាំបាច់របស់គណៈមជ្ឈិម ។ មន្ទីរស-៧១ គឺត្រូវបានរៀបចំជាមន្ទីរ និងអង្គភាពតូចៗផ្សេងទៀតដែលមានលេខកូដ "ក" គឺ ក១, ក៣, ក៤ ...។ល។

[១៤:៥៥:៤៥]

"ក១" គឺយើងហៅថាមន្ទីរអង្គការ ហើយគឺវាជាទីតាំង និងទីស្នាក់នៅរបស់ ប៉ុល ពត ។ ជាការិយាល័យ និងទីស្នាក់នៅរបស់ ប៉ុល ពត ។ "ក៣" ក៏យើងហៅថាមន្ទីរអង្គការផងដែរ ហើយ នួន ជា និង ខៀវ សំផន បានរស់នៅ ហើយ "ក៣" មានទីតាំងនៅក្រោយវាំង។ ហើយ "ក១" គឺនៅខាងត្បូងនៃមន្ទីរសភាថ្មីយើងសព្វថ្ងៃ ។ ហើយ "ក៣" នេះផងដែរនៅក្នុង មានទីតាំងនៅក្នុងទីក្រុង ហើយគណៈ សមាជិករបស់គណៈអចិន្ត្រៃយ៍គឺមាននៅ មានការស្នាក់នៅនៅទីនោះ ហើយប្រជុំនៅទីនោះ ។

"ក៤"គឺជាមន្ទីរភស្តុភារ ដើម្បីរៀបចំការងាររបស់គណៈអចិន្ត្រៃយ៍ក្នុងការផ្គត់ផ្គង់ការដឹកជញ្ជូន និងបញ្ហាផ្សេងៗទៀត ។ "ក៤" គឺជាសាលានយោបាយ ជាទីកន្លែងដែលបក្សកុម្មុយនីស្តកម្ពុជាបណ្តុះបណ្តាលកម្មាភិបាល ។

**ស៖** ខ្ញុំសូមកាត់នៅត្រង់ទីនេះ លោកបាននិយាយ "ក៤" ពីរដង ។

**ឆ៖** "ក៥" គឺជាសាលានយោបាយ ។ "ក៦" គឺសាលាបក្ស ដែលនៅទីនេះមានការបណ្តុះបណ្តាលបន្ថែមដល់កម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ។ "ក៧" គឺជាអង្គភាពអ្នកនាំសារ របស់គណៈមជ្ឈិម មានទីតាំងនៅលើផ្លូវសុធារស ហើយទល់មុខនឹងសារមន្ទីរជាតិ ។

**ស៖** ជាថ្មីម្តងទៀត ប្រសិនបើខ្ញុំសូមលើកឡើងទៅលើរបាយការណ៍របស់លោក ក្រេក អេតឆេសាន់ គឺលោកបាននិយាយពិស្តារដោយរៀបរាប់អំពីមន្ទីរ "ក" ផ្សេងៗ ។ ប្រហែលវាមិនមានភាពចាំបាច់សម្រាប់អង្គសវនាការក្នុងស្តាប់នូវមន្ទីរទាំងអស់នោះទេ ។ ដូច្នេះអក្សរ "ក១ ដល់ ក៧" នោះ តើយើងអាចប្រាប់ តើលោកអាចប្រាប់បានឬទេ? ថា តើមានមន្ទីរ "ក" ទាំងអស់ប៉ុន្មាន? ហើយប្រសិនបើលោកដឹងថាមានបុគ្គលិកចំនួនប៉ុន្មានធ្វើការនៅមន្ទីរទាំងអស់នោះ?

**ឆ៖** នៅក្នុងរបាយការណ៍របស់ខ្ញុំ ខ្ញុំបានលើកឡើងមន្ទីរ “ក” ចំនួនជាងម្ភៃ ដែលមានមុខនាទីក្នុងការផ្តល់សេវាផ្សេងៗ និងលក្ខខណ្ឌរបស់មជ្ឈិមបក្ស ។ នៅក្នុងឯកសារដែលបង្កើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលយើងមាននោះ យើងឃើញមានមន្ទីរផ្សេងៗទៀតដែលមានលេខ “ក” ។ យើងមិនទាន់បានធ្វើការបង្កើតថាតើមានមន្ទីរ “ក” ទាំងអស់នោះចំនួនប៉ុន្មាននោះទេ? ដូចដែលមន្ទីរផ្សេង មួយចំនួនដែលខ្ញុំបានរៀបរាប់នៅក្នុងនេះ ដែលមានតួនាទីបម្រើមជ្ឈិមបក្ស ហើយវាជាអង្គការមួយធំ ។ ហើយចំពោះកម្មាភិបាលចំនួនប៉ុន្មាននោះ ខ្ញុំមិនអាចធ្វើការសន្និដ្ឋានអំពីចំនួនបុគ្គលិកនៅមន្ទីរ “ក” ទាំងអស់នោះ តើមានចំនួនប៉ុន្មាននោះទេ?

[១៤:៥៩:០៨]

**ស៖** សូមអរគុណចំពោះមន្ទីរ “ក” ចំនួនម្ភៃ ដែលលោកបានរៀបរាប់នៅក្នុងរបាយការណ៍របស់លោក ។ តើលោកអាចអាចជម្រាបយើងខ្ញុំបានដែរឬទេ? ថាបុគ្គលិកពីមន្ទីរទាំងអស់នោះ គឺស្ថិតនៅក្រោមការសម្រិតសម្រាំងផ្សេងៗ ដូចដែលលោករៀបរាប់ដែរឬទេ? ហើយប្រសិនបើមែននោះនៅក្នុងការស្រាវជ្រាវរបស់លោក តើការសម្រិតសម្រាំងនោះ តើមានធ្វើឡើងនៅស-២១ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអាចរៀបរាប់បាន ជាការពិត គឺមន្ទីរ “ក” មួយចំនួនដែលខ្ញុំរៀបរាប់នៅក្នុងរបាយ-ការណ៍របស់ខ្ញុំ គឺជាមន្ទីរអប់រំ ។ បានន័យថា គឺជាមន្ទីរជំរំបង្ខំឲ្យធ្វើការ ហើយប្រើប្រាស់សម្រាប់អប់រំ និងដាក់វិន័យបុគ្គលនៅក្នុងមជ្ឈិមបក្ស ឬក៏នៅមន្ទីរ និងអង្គការផ្សេងៗ ដែលពួកគេមិនបានគោរពតាមក្រឹត្យក្រម ឬក៏មានការសង្ស័យទៅលើប្រវត្តិរូបផ្សេងៗ ឬក៏អ្នកដែលមានការឆ្លើយដាក់ពីបុគ្គលមុនដែលត្រូវបានគេសម្រិតសម្រាំង ។

ដូច្នេះ យើងឃើញថា មានមន្ទីរអប់រំច្រើនដែលគ្រប់គ្រងដោយមជ្ឈិមបក្ស ជាពិសេសនៅក្នុងក្រោមការគ្រប់គ្រងរបស់ ផេង ។ សូមកែតម្រូវ គឺ ប៉ង់ ។ ហើយចំពោះស-២១ យើងជឿថាបុគ្គលមកពីមន្ទីរ “ក” មួយចំនួនទាំងអស់នោះ គឺក្លាយទៅជាជនរងគ្រោះនៅស-២១ ។

**ស៖** ដើម្បីធ្វើជាកំណត់ត្រារបស់តុលាការ លោកបានលើកឡើងឈ្មោះ ផេង គឺ ប៉ង់ តើលោកអាចធ្វើការប្រកប ថាតើឈ្មោះរបស់គាត់ពេញអ្វី ដើម្បីឲ្យយើងដឹង? ហើយយើងដឹងហើយថា មានការតវ៉ាផ្សេងៗអំពីឈ្មោះនេះ ។

**ឆ៖** ប៉ង់ គឺ *P-A-N-G* ។

**ស៖** ប៉ង់ នេះគឺជាឈ្មោះបដិវត្តន៍របស់ ឈឹម សំអោក ឬក៏យ៉ាងម៉េច? គឺប្រកប *ស៊ី* គឺនេះជាការប្រកបទៅលើឈ្មោះនេះ ។

[១៥:០២:០៧]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា គឺត្រឹមត្រូវហើយ គឺឈ្មោះហ្នឹងមែន ។

**ស៖** លោកអាចប្រាប់ទេ តើគាត់ទទួលវាសនាយ៉ាងម៉េចដែរចំពោះ ប៉ង់ នោះ?

**ឆ៖** ប៉ង់ ត្រូវបានជាប់ឃុំនៅក្នុងស-២១ ក្រោយពីគាត់បានបញ្ជូនមនុស្សផ្សេងៗមក ស-២១ ។

**ស៖** លោកប្រធាន ថាតើលោកប្រធានចង់ធ្វើការឈប់សម្រាកសិន ឬក៏យ៉ាងម៉េច? ខ្ញុំមានសំណួរមួយចំនួនក្នុងការសួរ ប៉ុន្តែខ្ញុំគិតថា ប្រហែលជាអង្គសវនាការចង់ធ្វើការឈប់សម្រាកសិន ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងបីម្ភៃនាទីសូមអញ្ជើញចូលមកវិញ ។ ដើម្បីតុលាការសម្របសម្រួលដល់អ្នកជំនាញដើម្បីគាត់បានមានកន្លែងសម្រាកសមរម្យ ។

*[សវនាការសម្រាកពីម៉ោង ១៥:០៣ នាទី ដល់ម៉ោង ១៥:២៣ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយជាកិច្ចបន្តនេះ សូមប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីសួរដល់លោកបណ្ឌិត ក្រេក អេតឆេសាន់ ដែលជាអ្នកជំនាញនៅចំពោះមុខនេះ ។ សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ មុននឹងខ្ញុំចាប់ផ្តើម ខ្ញុំចង់រំឭកដល់លោក លោកស្រីចៅក្រម និងភាគីទាំងអស់អំពីឯកសារទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ ដែលខ្ញុំបានជូនដំណឹងលោក លោកស្រីចៅក្រមពីមុនមកនុ៎ង គឺថា មានកូនសៀវភៅមួយទាក់ទងទៅនឹងអង្គហេតុនេះ ដែលខ្ញុំនឹងផ្តល់ជូនដូចដែលអ្វីដែលខ្ញុំបានផ្តល់ជូនកាលពីមុនទាក់ទងទៅនឹងសៀវភៅ ហើយនិងរូបថតនៃស-២១ នោះ ប៉ុន្តែ ខ្ញុំនឹងមិនធ្វើការចែកចាយនៅពេលនេះទេ គ្រាន់តែរំឭកតែប៉ុណ្ណោះ ។

**ស៖** លោក ក្រេក អេតឆេសាន់ តើលោកអាចប្រាប់យើងខ្ញុំបានទេ ថាតើមានកំណត់ហេតុនៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ប៉ុន្មាន ដែលនៅមានបន្សល់ទុករហូតដល់ពេលនេះ?

**ឆ៖** ទៅតាមការចងចាំរបស់ខ្ញុំ លោកសហព្រះរាជអាជ្ញា ការិយាល័យសហព្រះរាជអាជ្ញាមានប្រហែល កំណត់ហេតុនៃអង្គប្រជុំនុំង ចំនួនប្រហែលម្ភៃរបស់គណៈអចិន្ត្រៃយ៍ ដែលរួមមានជាផ្នែកតូចមួយនៃកំណត់ហេតុនៃអង្គប្រជុំនោះ ។

**ស៖** តើមានអ្វីដែលបណ្ដាលឲ្យលោកធ្វើការសន្និដ្ឋានថា ឯកសារនេះ គឺជាឯកសារដែលមានចំនួនតូច ដែលជាកំណត់ហេតុនៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍នោះ?

**ឆ៖** ជាការពិតណាស់ លោកសហព្រះរាជអាជ្ញា ការជ្រើសរើសនៃកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ គឺបានមកពីរយៈពេលតូចមួយ ចន្លោះពេលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រហែលជានៅចុងឆ្នាំ១៩៧៥ និងពាក់កណ្ដាលដើមនៃឆ្នាំ១៩៧៦ ។ កាលបរិច្ឆេទនៃកំណត់ហេតុអង្គប្រជុំមួយចំនួនបានស្នើឡើងថា គណៈអចិន្ត្រៃយ៍បានជួបជាញឹកញាប់នៅពេលមួយខ្លះ ជួនកាលពីរដងក្នុងមួយថ្ងៃ ដើម្បីធ្វើការប្រជុំទៅលើប្រធានបទផ្សេងៗ ។ មិនមានហេតុផលអ្វីដែលមិននាំឲ្យយើងជឿថា គណៈអចិន្ត្រៃយ៍មិនបានបន្តទៀតទេនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ នៅពេលដែលពួកគេធ្វើការប្រជុំជាញឹកញាប់ទៅតាមគម្រោងកាលបរិច្ឆេទរបស់គេ ។ ប៉ុន្តែ ដោយសារតែមានបញ្ហាសង្គ្រាម គោលនយោបាយនៃភាពសម្ងាត់របស់កម្ពុជាប្រជាធិបតេយ្យនិងការព្យាយាម ការកំណត់ទៅលើការបំផ្លាញឯកសារ ហើយនិងបណ្ណសារផ្សេងៗមុនពេលដែលភ្នំពេញបានបែក ដែលបានធ្វើឡើងកាលពីថ្ងៃទី៦ និងថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩នោះ ឯកសារភាគច្រើនមួយចំនួនធំត្រូវបានបាត់បង់អស់ ។

[១៥:២៧:៤៧]

**ស៖** សូមអរគុណ ។ ទាក់ទងទៅនឹងសេចក្ដីសម្រេចកាលពីមុនមកនោះ ខ្ញុំមិនចង់លើកឡើងអំពីកំណត់ហេតុនីមួយៗនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ទេ ក៏ប៉ុន្តែ លោកអាចប្រាប់យើងបានទេ ជាលក្ខណៈទូទៅ តើអ្នកគេជាអ្នកចូលរួមអង្គប្រជុំគណៈអចិន្ត្រៃយ៍នោះ? ថាតើពួកគេជាសមាជិកគណៈអចិន្ត្រៃយ៍តែមួយទេ ឬក៏មានអ្នកមកពីក្រៅដែលមិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ? ហើយជាទូទៅ តើពួកគេពិភាក្សាអំពីអ្វីដែរនៅក្នុងអង្គប្រជុំនោះ ហើយពួកគេចេញសេចក្ដីណែនាំអ្វីខ្លះ?

**ឆ៖** បាទ,ពិតជាបានលោកសហព្រះរាជអាជ្ញា ។ អង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍តែងតែចូលរួមដោយសមាជិកយ៉ាងហោចណាស់ចំនួនពីរ ឬក៏ច្រើនជាងពីរនៃសមាជិកអចិន្ត្រៃយ៍ គណៈអចិន្ត្រៃយ៍ ។

ហើយជាទូទៅ គឺសមាជិកគណៈអចិន្ត្រៃយ៍ជាច្រើន មានការទទួលខុសត្រូវផងដែរ ជាលេខាភូមិភាគ ។ ដូច្នេះហើយ ជាទូទៅគឺពួកគេមិនសូវមានវត្តមាននៅទីក្រុងភ្នំពេញទេ ហើយម្តងម្កាល គឺថាពួកគេបានចូលអង្គប្រជុំគណៈអចិន្ត្រៃយ៍នោះ ។

ចំណែក ខៀវ សំផន គឺគាត់មិនមែនជាសមាជិកនៃគណៈអចិន្ត្រៃយ៍ទេ ។ ក៏ប៉ុន្តែ ដោយមានការជ្រើសរើសទៅលើកំណត់ហេតុអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ ជាទូទៅគឺគាត់ចូលរួមនៅក្នុងអង្គប្រជុំនោះ ។ ប្រសិនបើខ្ញុំនៅចងចាំមិនខុសទេនោះ គឺមានតែ នួន ជា ទេ ដែលចូលរួមប្រជុំនៅក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍ទ្រុំងជាង ខៀវ សំផន ។

ជាញឹកញាប់ កម្មាភិបាលជាន់ខ្ពស់មកពីភូមិភាគ មកពីក្រសួងនានា និងឬមកពីផ្នែកយោធានឹងត្រូវបានអញ្ជើញឲ្យចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ដើម្បីរាយការណ៍ស្ថានការណ៍ និងទទួលនូវសេចក្តីណែនាំពីគណៈអចិន្ត្រៃយ៍ ។ ប្រធានបទផ្សេងៗដែលត្រូវបានពិភាក្សាដែលត្រូវបានពិភាក្សានៅក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍ និងដែលនៅក្នុងកំណត់ហេតុដែលយើងមាននេះ គឺវាមានចំនួនច្រើន គឺលាតសន្ធឹងគ្របដណ្តប់គ្រប់ប្រធានបទទាំងអស់ តាំងពីនយោបាយ ការចាត់តាំង សេដ្ឋកិច្ច យោធា និងកិច្ចការសន្តិសុខ នយោបាយអន្តរជាតិ ។

ជាសង្ខេបទៅ គឺប្រធានបទសឹងតែទាំងអស់ត្រូវបានពិភាក្សាទាក់ទងទៅនឹងប្រតិបត្តិការរបស់រដ្ឋាភិបាលជារៀងរាល់ថ្ងៃ អំពីកិច្ចការទូទាំងប្រទេសជាដើម ។

[១៥:៣០:៥៩]

**ស៖** សូមអរគុណ ។ ខ្ញុំសូមឲ្យលោកពិភាក្សាទៅតាមបញ្ជីដែលខ្ញុំនឹងរៀបឡើងអំពីវិធីសាស្ត្រផ្សេងៗ ដែលគណៈអចិន្ត្រៃយ៍បានធ្វើទំនាក់ទំនងជាមួយនឹងថ្នាក់ក្រោម នៅទូទាំងប្រទេសកម្ពុជា និងនៅក្នុងជួរបក្ស ។ ជាដំបូងតើខ្ញុំអាចឲ្យខ្ញុំពិភាក្សាទៅលើសេចក្តីណែនាំ ដែលត្រូវបានបញ្ជូនទៅឲ្យគ្រប់ឋានៈទាំងអស់ត្រូវបានផ្ញើចេញពីគណៈអចិន្ត្រៃយ៍ ហើយប្រហែលជាលោកអាចនិយាយយោងទៅលើឯកសារចំនួនពីរ ជាពិសេសនោះ គឺឯកសារ៣៦ នៅក្នុងឧបសម្ព័ន្ធរបស់លោក គឺចេញពីមន្ទីរ៨៧០ ដែលមានចំណងជើងថា “ការប្រកាសអំពីការសិក្សា និងការប្រយុទ្ធផ្តាច់ប្តូរជាមួយនឹងយួន” និងឯកសារ ១៣៨ ចេញមកពីមន្ទីរ៨៧០ ពីរថ្ងៃក្រោមមកនោះ គឺនៅថ្ងៃទី៣ ខែ១ ឆ្នាំ៧៩ ដែលមានចំណងជើងថា “សេចក្តីណែនាំពីមន្ទីរ៨៧០” ។

ទាក់ទងទៅនឹងការពិភាក្សាថ្ងៃនេះ ខ្ញុំមិនចង់ធ្វើការអាននូវលេខ *ERN* ដែលជាលេខយោងនៃ

ឯកសារទាំងពីរនេះទេ ។ គឺឯកសារលេខ៣៦ និងឯកសារលេខ១៣៨ ទាក់ទងទៅនឹងសេចក្តីណែនាំដែលបានបញ្ជូនចេញមកពីគណៈអចិន្ត្រៃយ៍ ។

**ឆ៖** បាទ, ពិតជាបានលោកសហព្រះរាជអាជ្ញា ។ ឯកសារទាំងពីរនេះ ត្រូវបានមន្ទីរ៨៧០ចេញនៅពេលដែលកម្ពុជាប្រជាធិបតេយ្យកំពុងចូលជួបនឹងវិបត្តិដ៏ធ្ងន់ធ្ងរមួយនោះ ។ ឯកសារទីមួយ ចុះថ្ងៃទី១ ខែមករា ឆ្នាំ៧៩ ដែលត្រូវបានចេញប្រហែលជាមួយសប្តាហ៍ក្រោយពីកងម្លាំងវៀតណាម បានចាប់ផ្តើមការវាយលុកឈ្លានពានទ្រង់ទ្រាយធំ ចូលទៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដោយប្រើទាហានទ័ពលើគោក ហើយនិងទ័ពជើងអាកាសផងដែរ ។ ហើយពេលនុ៎ងឯង គឺកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យនុ៎ងត្រូវបានហ៊ុំព័ទ្ធនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ។

នៅថ្ងៃទី១ ខែមករានោះ គឺមេដឹកនាំមានការយល់ដឹងច្បាស់ថា ពួកគេនឹងអាចបាត់បង់ទីក្រុងភ្នំពេញ ហើយត្រូវដកថយខ្លួនទៅធ្វើសង្គ្រាមឧទ្ទាមវិញ ។ ប៉ុន្តែ ពួកគេមិនទាន់បានធ្វើការសារភាពអំពីបញ្ហាចំណុចនេះ ប្រាប់ដល់កម្មាភិបាល និងប្រជាជនរបស់ពួកគេនៅឡើយទេ ទោះបីពួកគេបានចាត់វិធានការប្រចាំដើម្បីទប់ទល់នឹងសភាពការណ៍ ដែលនឹងកើតឡើងជាបច្ច័យនោះ ។ ឯកសារជាក់លាក់មួយនេះ ត្រូវបានបែងចែងពីភ្នំពេញទៅឲ្យតាមអង្គភាពផ្សេងៗរបស់អង្គការនៃបក្សកម្ពុជាប្រជាធិប-តេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា ។ ហើយបានស្នើឲ្យ អំពាវនាវឲ្យប្រជាជនស៊ីវិលទាំងអស់ចាប់ផ្តើមធ្វើសង្គ្រាមឧទ្ទាមប្រឆាំងនឹងកងកម្លាំងឈ្លានពានរបស់វៀតណាម ។

ឯកសារទីពីរ ដែលលោកបានលើកឡើងអម្បាញ់មិញនេះ បានចេញនៅថ្ងៃទី៣ ខែ១ ឆ្នាំ១៩៧៩ មានន័យថា ពីរថ្ងៃបន្ទាប់ពីឯកសារទីមួយដែលបានចេញនោះ ។ ឯកសារនេះបានអំពាវនាវឲ្យកងកម្លាំងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យ បន្តតស៊ូនឹងកងកម្លាំងឈ្លានពានរបស់វៀតណាម ហើយបានកោះហៅអំពាវនាវផងដែរ ឲ្យកងកម្លាំងធ្វើការដកថយ ដើម្បីរៀបចំមូលដ្ឋានសង្គ្រាមឧទ្ទាម ។ ឯកសារនេះដូចជាត្រូវបានផ្សព្វផ្សាយទៅឲ្យតាមអង្គការផ្សេងៗរបស់អង្គភាពនៃកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា ។

**ស៖** សូមអរគុណ ។ តើខ្ញុំអាចសួរលោកបានទេនៅក្នុងស្រាវជ្រាវរបស់លោក? តើលោកមានបានរកឃើញសេចក្តីណែនាំប្រហាក់ប្រហែលគ្នានេះដែរឬទេ? ខ្ញុំមានន័យថា គឺសេចក្តីណែនាំដែលបានចេញមកពីគណៈអចិន្ត្រៃយ៍ ហើយដែលត្រូវបានបញ្ជូនទៅឲ្យគ្រប់ស្រទាប់ទាំងអស់នៃរចនាសម្ព័ន្ធនោះ?

**ឆ៖** ឯកសារប្រភេទនេះ គឺជាឯកសារដែលមិនសូវសម្បូរទេ ហើយក៏មិនសូវមានសល់ប៉ុន្មានដែរ ក៏ប៉ុន្តែមានឧទាហរណ៍មួយចំនួនដែលយើងអាចដកស្រង់មកបាន ដែលហាក់បីដូចជាបង្ហាញថាបានទទួលការចែកចាយទ្រង់ទ្រាយធំ ។ ដែលជាប្រាកដណាស់ គឺមានការចែកចាយនៅក្នុងថ្នាក់លើក្បាលម៉ាស៊ីនថ្នាក់លើ ឬមួយក៏អាចនឹងចែកចាយដល់គ្រប់អង្គភាពទាំងអស់ ។ ហើយខ្ញុំនឹងដកស្រង់នូវជាឧទាហរណ៍មួយ គឺឯកសារដែលពីមុនមកយើងបានពិភាក្សារួចហើយនោះ ដែលចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលមានចំណងជើងថា "សេចក្តីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងមួយចំនួន" ។ ដែលនៅក្នុងឯកសារនោះទោះបីជាឯកសារនោះត្រូវបានចេញពីគណៈមជ្ឈិមក៏ដោយ សម្រាប់ខ្ញុំ ខ្ញុំយល់ថា នេះគឺជាផលិតផលនៃគណៈអចិន្ត្រៃយ៍ ។ បើសិនជាតុលាការអនុញ្ញាត ខ្ញុំអាចនឹងផ្តល់លេខ ERN នៃឯកសារនេះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រហែលជាលេខហ្នឹង គឺថាមាននៅក្នុងបញ្ជីហើយ ។

[១៥:៣៨:១៥]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

គឺឯកសារដែលមានលេខរៀង៣៧ នៅក្នុងឧបសម្ព័ន្ធនៃឯកសារ E55.1 ។ សូមអរគុណ ។

**ស៖** ដើម្បីធ្វើការពិភាក្សាលើបញ្ហាផ្សេងទៀត ដែលគណៈអចិន្ត្រៃយ៍ធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងថ្នាក់ក្រោមរបស់ខ្លួន តើលោកអាចប្រាប់បានទេ លោកបណ្ឌិត អេតឆេសាន់? ធ្វើការពិភាក្សាអំពីវគ្គបណ្តុះបណ្តាលនៅសាលាបណ្តុះបណ្តាលរបស់បក្សដែលអ្វីបានកើតឡើងនៅទីនោះ ទៅតាមការយល់ដឹងរបស់លោក?

[១៥:៣៩:០៥]

**ឆ៖** សាលាបណ្តុះបណ្តាលរបស់បក្ស គឺជាទីកន្លែងមួយដែលកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជាត្រូវបានបណ្តុះបណ្តាលអំពីមាគ៌ា ដែលជាភាសាសាមញ្ញយើងហៅថា "ជាគោលនយោបាយរបស់បក្ស និងរបស់រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ" ។ វគ្គបណ្តុះបណ្តាលនេះគឺមានកើតឡើងជាប្រចាំសម្រាប់កម្មាភិបាលពីអង្គភាពទាំងអស់នៃអង្គការរបស់កម្ពុជាប្រជាធិបតេយ្យ ។

មិនត្រឹមតែនៅថ្នាក់មជ្ឈិមនោះទេ ប៉ុន្តែ មានពាក់ព័ន្ធដល់កម្មាភិបាលផ្សេងៗមកពីភូមិភាគ មកពីតំបន់ មកស្រុក... ។ល។

ដូច្នេះ ហើយគ្រប់ៗគ្នា គឺអាចនឹងទទួលបាននូវការវាយតម្លៃអំពីមាគ៌ា គោលនយោបាយរបស់បក្ស និងរបស់រដ្ឋ ។ វគ្គបណ្តុះបណ្តាលនេះត្រូវបានដឹកនាំឡើង និងបង្រៀនដោយ នួន ជា និងឬ លោក ខៀវ សំផន ។

**ស៖** យើងចូលទៅដល់បក្សកុម្មុយនីស្តកម្ពុជា គឺទាក់ទងទៅមីទិ្ទង ដែលបានរៀបចំនៅទីក្រុងភ្នំពេញ នៅពហុកីឡាដ្ឋានជាតិ ។ តើលោកអាចរៀបរាប់ថានេះជាវិធីមួយដែលគណៈអចិន្ត្រៃយ៍ធ្វើការទំនាក់ទំនងជាមួយបណ្តាជួរថ្នាក់ក្រោម?

**ឆ៖** លោកសហព្រះរាជអាជ្ញា ពហុកីឡាដ្ឋានជាតិ គឺមីទិ្ទងនៅទីនោះ គឺត្រូវបានរៀបចំដោយគណៈមជ្ឈិម គឺមានតួនាទីស្រដៀងគ្នាទៅនឹងសាលារបស់បក្ស ។ ប៉ុន្តែ មានទំហំធំជាងសាលារបស់បក្ស ។

យើងឃើញមានក្រុមជាច្រើនដែលមាននៅក្នុងពហុកីឡាដ្ឋាន ហើយមានកម្មាភិបាល មានយុទ្ធជនដែលបានប្រមូលផ្តុំនៅទៅនោះ ។ ហើយមានការបណ្តុះបណ្តាលនឹងបង្រៀនអំពីស្នាដៃ និងគោលបំណងរបស់បដិវត្តន៍ គោលនយោបាយរបស់បក្សផ្សេងៗ ។ នេះគឺជាព្រឹត្តិការណ៍រៀបចំមួយទៀងទាត់ផងដែរ ។ ហើយខ្ញុំថានៅក្នុងសំណុំរឿង គឺយើងឃើញមានរូបភាពនៃមីទិ្ទងដែលបានថតទុកនៅពេលនោះ ហើយដែលបង្ហាញមានការចូលរួមជាញឹកញាយ ដោយគណៈអចិន្ត្រៃយ៍ដែលចូលរួមក្នុងការលើកឡើងនៅក្នុងមីទិ្ទងនោះ ។

[១៥:៤២:៣២]

**ស៖** សូមអរគុណ ។ យើងចូលទៅដល់វិធីមួយទៀតដែលគណៈអចិន្ត្រៃយ៍ធ្វើការទាក់ទងទៅក្នុងជួររបស់ខ្លួនទៅថ្នាក់ក្រោម ។ ហើយខ្ញុំចង់ឲ្យលោក អេតធេសាន់ រៀបរាប់អំពីវិទ្យុរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ? ហើយប្រហែលជា ប្រសិនបើលោកអាចធ្វើទៅបាន សូមឲ្យលោករៀបរាប់ ដោយរួមជាមួយឯកសារ៥៥ នៅក្នុងឧបសម្ព័ន្ធរបស់លោកដែលមានចំណងជើងថា "កំណត់ប្រជុំទាក់ទងទៅនឹងការឃោសនារបស់គណៈអចិន្ត្រៃយ៍, ថ្ងៃ៨ ខែមីនា ឆ្នាំ១៩៧៦" ។

**ឆ៖** បាទ, លោកសហព្រះរាជអាជ្ញា ។ ឯកសារមួយនេះ គឺចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ គឺកំណត់ប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលមានចំណងជើងថា "កំណត់ប្រជុំលើការងារឃោសនា" គឺនៅក្នុងកំណត់ប្រជុំនេះ គឺបានកត់ទុកអំពីការណែនាំរបស់មជ្ឈិមបក្សដល់ផ្នែកអង្គការឃោសនាផ្សេងៗថាតើពួកគេគួរតែធ្វើការចែកជូនដល់ប្រជាជននូវព័ត៌មានយ៉ាងម៉េច អំពីការបោះឆ្នោតដែលត្រូវរៀបចំឡើង

នៅក្នុងកម្ពុជាប្រជាធិបតេយ្យ គឺនៅថ្ងៃទី២២ ខែ៣ ឆ្នាំ១៩៧៦? ហើយនៅក្នុងនោះគឺមានរៀបរាប់ពិស្តារអំពីខ្លឹមសារ ដែលមានរៀបរាប់អំពីពេលវេលាផ្សេងៗ ថាពេលណាដែលពួកគេត្រូវចែកចាយព័ត៌មាន ហើយនិងទម្រង់យ៉ាងម៉េចដែលត្រូវរៀបចំឡើងដើម្បីចែកចាយ ថាតើផ្សព្វផ្សាយតាមវិទ្យុ ឬក៏ចែកចាយតាមរយៈការប្រជុំទល់មុខគ្នា ឬក៏ធ្វើការប្រជុំដើម្បីបញ្ជូនព័ត៌មានទាំងអស់នោះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំសូមធ្វើការអភ័យទោស ប៉ុន្តែ ខ្ញុំសូមស្នើសុំថា នៅពេលដែលយោងទៅដល់ឯកសារនោះ សូមឲ្យគាត់បង្ហាញលេខជើងទំព័រដើម្បីឲ្យយើងមានភាពងាយស្រួលក្នុងការរកឯកសារដែលលោក ក្រេក អេតឆេសាន់ ទើបតែបានលើកឡើងនេះ ។

[១៥:៤៥:៣៦]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំអត់មានលេខជើងទំព័រដែលមានសរសេរនៅក្នុងតារាងឯកសារនោះទេ ហើយគឺថាចំណុចនេះគឺមិនអាច ខាងសហព្រះរាជអាជ្ញា និងខាងមេធាវីការពារក្តីមិនអាចប្រាប់បានទេលើកលែងតែខាងលោក ក្រេក អេតឆេសាន់ អាចប្រាប់ទៅលើបញ្ហានេះបាន ។ គឺយើង គឺស្នើសុំឲ្យដូចដែលមេធាវីការពារក្តីអ៊ីចឹង គឺថាឲ្យមានប្រាប់លេខជើងទំព័រឲ្យយើងខ្ញុំដឹងផង ។

**ប្រធានអង្គជំនុំ៖**

លោកបណ្ឌិតអាចប្រាប់ឲ្យលេខជើងទំព័រឯកសារផងបានទេ?

**លោក ក្រេក អេតឆេសាន់៖**

លោកប្រធានឯកសារនេះ គឺយោងនៅក្នុងរបបាយការណ៍ ប៉ុន្តែ ខ្ញុំមិនមានវិធីដែលងាយស្រួលនៅក្នុងការស្វែងរកផ្នែកជាក់លាក់ ឬក៏លេខយោងជាក់លាក់ ។ ប៉ុន្តែគឺថា ប្រសិនបើលោកអង្គសវនាការចង់បាននោះគឺថា ខ្ញុំអាចធ្វើការចំណាយពេលក្នុងការស្វែងរកលេខនេះបាន ។ ដើម្បីជាប្រយោជន៍ ចំពោះគ្រប់ភាគីទាំងអស់ យើងរកឃើញការប្រើប្រាស់ពាក្យសាមញ្ញនៅលើឯកសារ *ភីឌីហ្វ* គឺលេខជើងទំព័រ៨៦ ។ អ៊ីចឹងភាគីត្រូវតែធ្វើការស្រាវជ្រាវតាមពាក្យនៅក្នុងទម្រង់ *ភីឌីហ្វ* ហើយនៅពេលនោះលេខជើងទំព័រហ្នឹងលោតឡើង ហើយបង្ហាញឲ្យឃើញ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ដូចដែលសហសេវិករបស់ខ្ញុំបានប្រាប់ខ្ញុំ គឺថាផ្នែកមួយចំនួនគឺវាលេចឡើងច្រើនដង ច្រើនសា

ដូច្នេះហើយ ហើយយើងក៏ឃើញថាចំណុចមួយនេះក៏លេចឡើងនៅក្នុងជើងទំព័រ៩២ ផងដែរ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តទៀតលោកតំណាងសហព្រះរាជអាជ្ញា ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊េត៖**

សូមអរគុណលោកប្រធាន ។ លោក អេតឆេសាន់ លោកបានរៀបរាប់ទៅលើបញ្ហាមួយចំនួនអំពីទស្សនាវដ្តីទង់បដិវត្តន៍របស់កម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំចង់សួរសំណួរមួយចំនួនទៅដល់លោកជាលក្ខណៈទូទៅ ។

**ស៖** តើលោកមានការយល់ឃើញយ៉ាងម៉េចថាទស្សនាវដ្តីនេះ ត្រូវបានគេបោះពុម្ពផ្សាយឬក៏អានជាញឹកញយប៉ុនណា? ហើយគេបោះពុម្ពផ្សាយ និងចែកជូនទៅដល់បុគ្គលណាខ្លះ?

[១៥:៤៨:៣៤]

**ឆ៖** បាទ,លោកសហព្រះរាជអាជ្ញា ។ ការយល់ឃើញរបស់ខ្ញុំគឺ ទស្សនាវដ្តីទង់បដិវត្តន៍គឺរៀបចំឡើង ដើម្បីផ្តល់ជូនទៅដល់សមាជិកពេញសិទ្ធិរបស់បក្ស ដោយគ្មានការលើកលែងទៅដល់សមាជិកណាមួយនោះទេ ។ ហើយគឺវាសិក្សាទៅលើព័ត៌មាន នៅពេលដែលសិក្សាទៅលើព័ត៌មាននៅក្នុងទង់បដិវត្តន៍នេះ គឺវាសម្រាប់សមាជិកបក្ស ហើយវាលើកឡើងអំពីចម្លើយសារភាពនៅស-២១ ផងដែរ ដែលកម្មាភិបាលសារភាពថា មានជាប់ពាក់ព័ន្ធ និងមានឥរិយាបទជាសត្រូវ ហើយគឺថាទស្សនាវដ្តីនេះត្រូវបានចែកជូនកម្មាភិបាលដែលនៅក្រោមបង្គាប់របស់ខ្លួន ។

**ស៖** ប្រហែលខ្ញុំអាចសូមឱ្យលោកបង្ហាញនូវសំណួរ ឆ្លើយចំពោះសំណួររបស់ខ្ញុំទាក់ទងទៅនឹងឯកសារទស្សនាវដ្តីទង់បដិវត្តន៍ ។ សំណួររបស់ខ្ញុំនោះ គឺថា ថាតើគណៈអចិន្ត្រៃយ៍ប្រើទង់បដិវត្តន៍នេះសម្រាប់បណ្តុះបណ្តាលគោលនយោបាយញឹកញាប់ប៉ុនណា ចំពោះមាគ៌ាបក្សនៅក្នុងទូទាំងប្រទេសនោះ? ហើយឯកសារពីរដែលខ្ញុំចាប់អារម្មណ៍នោះ គឺឯកសារលេខ៤៦ នៅក្នុងឧបសម្ព័ន្ធទាក់ទងទៅនឹងទស្សនាវដ្តីទង់បដិវត្តន៍ ថ្ងៃខែមិថុនា ឆ្នាំ១៩៧៧ ហើយឯកសារ៤៨ ទាក់ទងទៅនឹងទង់បដិវត្តន៍បោះពុម្ពពិសេស ខែធ្នូ ទៅដល់ខែមករា ឆ្នាំ១៩៧៨ ។ ខ្ញុំសួរលោក ថាតើលោកអាចឆ្លើយតបទៅនឹងសំណួរទាក់ទងទៅនឹងទង់បដិវត្តន៍ពីរនេះដែរឬទេ?

**ឆ៖** បាទ, លោកសហព្រះរាជអាជ្ញា ។ ឯកសារទង់បដិវត្តន៍ទាំងពីរនេះ គឺបោះពុម្ពក្នុងខែមិថុនា ឆ្នាំ១៩៧៧ ។ ហើយឯកសារដំបូងនោះ គឺវាជាឧទាហរណ៍មួយដែលគួរឱ្យចាប់អារម្មណ៍នៅក្នុង

អត្ថបទដែលមានសរសេរនៅក្នុងទង់បដិវត្តន៍មជ្ឈិមបក្ស គឺបានលើកឡើងអំពីទង់ពណ៌ក្រហមដែលជាទីគោរពនៅក្នុងថ្នាក់ស្រុកនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ ហើយគណៈមជ្ឈិម គឺបានចាត់ទុកអំពីឥរិយាបទផ្សេងៗដែលបង្ហាញនៅក្នុងទង់បដិវត្តន៍ ហើយបានលើកឡើងអំពីគោលការណ៍ "បីតោនក្នុងមួយហិកតា" ដែលជាគោលការណ៍ផលិតកម្ម ។ ហើយបានលើកឡើងនឹងក្តោបក្តាប់គោរពតាមគោលនយោបាយរបស់បដិវត្តន៍ ហើយបានលើកឡើអំពីថ្នាក់ស្រុក ស្រុកត្រាំកក់ និងកំពង់ត្រឡាច ។ ស្រុកទាំងអស់នោះ គឺអនុវត្តនៅក្នុងជួរនយោបាយ ជួរបដិវត្តន៍របស់បក្សហើយវាជាគំរូ ។ បន្ទាប់ពីការផ្តល់នូវការកោតសរសើរចំពោះស្រុកទាំងអស់នោះ យើងឃើញមានអត្ថបទវែងដែលតម្រូវឲ្យធ្វើការស្វែងរក និងសម្លាប់សត្រូវស៊ីរូងផ្ទៃក្នុង ហើយដោយប្រើខ្លឹមសារដូចដែរតទៅនេះ៖

វិធានការដាច់ខាត ហើយមិនមានការអត់ឱនណាមួយ ហើយធ្វើការឡើងដោយមិនមានការស្ទាក់ស្ទើរ ។ ភាសានេះ គឺបានបកស្រាយដោយកម្មាភិបាលនៅទូទាំងប្រទេស ថាជាសញ្ញាមួយក្នុងការបង្កើននូវកម្រិតនៃការសម្រិតសម្រាំង ។ ហើយបន្ថែមពីនោះ គឺអត្ថបទនេះ គឺបន្តកំណត់នូវប្រភពនៃសត្រូវផ្សេងៗនៅក្នុងចំណោមប្រជាជនថ្មី ។ ហើយគឺអ្នកដែលជាប្រជាជនដែលជម្លៀសពីទីក្រុង ដែលត្រូវបានគ្រប់គ្រងដោយរដ្ឋនេះក្រោយពេលដែលរដ្ឋនេះបានចាប់យកអំណាច ។

ឧទាហរណ៍ទីពីរ គឺទង់បដិវត្តន៍ការបោះពុម្ពពិសេស បោះពុម្ពខែធ្នូ ឆ្នាំ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៨ គឺវាមានលក្ខណៈស្រដៀងគ្នានេះដែរ គឺបានបោះពុម្ពផ្សាយអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទៅដល់សមាជិករបស់ខ្លួន ។ គឺយើងគួរតែរំឭកថា បញ្ហានៃទង់បដិវត្តន៍នេះ គឺបោះពុម្ពឡើងក្នុងពេលដែលមានបញ្ហាវឹកវរនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារតែនៅពេលនោះ វៀត-ណាមគឺបានធ្វើការឈ្លានពានខាងផ្នែកយោធានៅក្នុងទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ ហើយបានចូលទៅដល់២០គីឡូម៉ែត្រនៅក្នុងទឹកដី ចាប់រាប់ពីព្រំដែននៃទឹកដីរវាងប្រទេសទាំងពីរ ។ បញ្ហាដែលលើកឡើងនៅក្នុងទស្សនាវដ្តីនេះ គឺលើកឡើងអំពីយោធាបដិវត្តន៍កម្ពុជាត្រូវការតតាំងចំពោះការឈ្លានពានរបស់យោធាប្រទេសផ្សេង ។ ហើយនៅក្នុងនោះដែរ ដែលចំណុចដែលគួរចាប់អារម្មណ៍នោះ គឺទង់បដិវត្តន៍បានបង្ហាញនឹងផ្តល់យុត្តិកម្មពន្យល់ទៅលើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលយើងដឹងថាវាមិនមានលក្ខណៈល្បីល្បាញនៅក្នុងចំណោមប្រជាជន ។ ឧទាហរណ៍ គឺការដកហូតទ្រព្យសម្បត្តិផ្សេងៗ ការកាប់សម្លាប់ទៅលើប្រជាជនវៀតណាម ហើយនឹងការបំផ្លិចបំផ្លាញនូវគ្រប់ថ្នាក់កម្មករ និងពលករផ្សេងៗ ។ ហើយបញ្ហាអត្ថបទទាំងអស់នេះ ដែលមាននៅក្នុងទង់បដិវត្តន៍ គឺក៏មាន

ផ្នែកជាច្រើនដែលបានរៀបរាប់ថា ហេតុអ្វីប្រជាជនមូលដ្ឋានមានលក្ខណៈនៅពីលើប្រជាជនថ្មី? ហេតុអ្វីបានជាប្រជាជនកសិករ គឺវាមានលក្ខណៈសំខាន់ជាងប្រជាជនមកពីទីក្រុង?

[១៥:៥៦:៤១]

**ស៖** សូមអរគុណ ។ ខ្ញុំសូមធ្វើការបំភ្លឺមួយចំណុច លោកបានលើកឡើងនៅក្នុងឯកសារទីមួយនៃឯកសារទាំងពីរនោះ គឺនិយាយអំពីទង់ក្រហមដែលបានផ្តល់ទៅដល់ស្រុកបី ។ ហើយស្រុកមួយលោកបានរៀបរាប់ថា ជាស្រុកកំពង់ត្រាឡាច ហើយមុននេះក្នុងការឆ្លើយតបសំណួរចំនួនពីរពីសហាវិកជាតិរបស់ខ្ញុំ លោកបានលើកឡើងថា ឌុច បានជ្រើសរើសកូនក្មេងតូចៗមកពីកំពង់ត្រឡាច ដើម្បីបម្រើជាបុគ្គលិកនៅស-២១ ។ ហើយថា តើក្មេងៗនេះមកពីក្នុងស្រុកហ្នឹង ឬក៏មកពីស្រុកពីរដែលលោកបានរៀបរាប់អម្បាញ់មិញនេះ?

**ឆ៖** កំពង់ត្រាឡាច ដែលបានលើកឡើងនៅក្នុងទស្សនាវដ្តី ចុះថ្ងៃទី៣០ មិថុនា ឆ្នាំ១៩៧៧ គឺជាខេត្តកំពង់ត្រាឡាច ដែលពួកក្មេងៗត្រូវបានជ្រើសរើសយកមកធ្វើជាបុគ្គលិកនៅស-២១ ។ (បាទ, សូមកែតម្រូវ គឺស្រុកកំពង់ត្រឡាច)

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើលោកអាចធ្វើការប្រកបឈ្មោះស្រុកឈ្មោះនោះបានដែរឬទេ?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

គឺ K-A-M-P-O-N-G T-R-A-L-A-C-H ការប្រកប ។

**ស៖** ហើយដើម្បីបញ្ចប់នូវអ្វីដែលយើងពិភាក្សាពីរបៀបនៃការទំនាក់ទំនងរបស់បក្សនេះទៅថ្នាក់ក្រោមនោះ ខ្ញុំសូមឲ្យលោកធ្វើការពិភាក្សា និងលើកឡើងអំពី ថាតើសមាជិកគណៈអចិន្ត្រៃយ៍នីមួយៗធ្វើដំណើរទៅតាមភូមិភាគ ដើម្បីប្រមូលព័ត៌មាននឹងចេញសេចក្តីណែនាំយ៉ាងម៉េច? ហើយបើលោកអាចសុំផ្តោតទៅលើឯកសាលេខ៥២ ដែលលោកបានលើកឡើងនៅក្នុងឧបសម្ព័ន្ធរបស់លោក គឺកំណត់ប្រជុំរបស់គណៈអចិន្ត្រៃយ៍របស់ខាងភូមិភាគពាយ័ព្យ គឺនៅថ្ងៃទី២០, ២៤ ឆ្នាំ១៩៧៥ ។

[១៥:៥៩:៣៨]

**ឆ៖** ពិតណាស់ លោកសហព្រះរាជអាជ្ញា ។ បាទ, នេះគឺជាឧទាហរណ៍ដ៏ចម្លែកមួយ នៅក្នុងកិច្ចកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ ពីព្រោះ ដោយមិនធ្វើការរាយការណ៍អំពីការប្រជុំមួយដែលកើត

មានឡើងនៅថ្ងៃណាមួយដែលមានសមាជិកមួយចំនួនចូលរួមនោះ ។ កំណត់ហេតុនៃប្រជុំរបស់គណៈអចិន្ត្រៃយ៍នេះ បានរាយការណ៍អំពីការធ្វើដំណើរទៅមូលដ្ឋានដែលគណៈអចិន្ត្រៃយ៍បានធ្វើទៅកាន់ភូមិភាគពាយ័ព្យ កាលពីខែសីហា នៃឆ្នាំ៧៥ ។

មិនមានការបង្ហាញឲ្យបានច្បាស់លាស់ទេ នៅក្នុងកំណត់ហេតុនៃប្រជុំនេះ បើសិនយើងពិនិត្យមើលទៅ ថាតើសមាជិកណាខ្លះនៃគណៈអចិន្ត្រៃយ៍ដែលត្រូវបានចូលរួមនៅក្នុងការធ្វើដំណើរមូលដ្ឋាននេះ? ក៏ប៉ុន្តែកំណត់ហេតុបានរៀបរាប់អំពីទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍នេះ តាមរយៈតំបន់មួយចំនួននៅក្នុងភូមិភាគពាយ័ព្យ ។ ជាគោលការណ៍ គឺនៅក្នុងជុំវិញទីក្រុងបាត់ដំបង ហើយកំណត់ហេតុនេះក៏បានធ្វើការរាយការណ៍អំពីការពិភាក្សាជាមួយនឹងកម្មាភិបាលជាន់ខ្ពស់នៅភូមិភាគពាយ័ព្យ ។

សេចក្ដីសន្និដ្ឋាននៃកំណត់ហេតុនេះ ដែលបានធ្វើការឡើងដោយគណៈអចិន្ត្រៃយ៍បន្ទាប់ពីការទស្សនកិច្ចបានបញ្ជាក់ថា គឺថាមានដីសម្រាប់ធ្វើកសិកម្មដ៏ច្រើននៅភូមិភាគពាយ័ព្យ ដែលអាចនឹងត្រូវយកមកធ្វើបាន មកប្រើប្រាស់ដើម្បីផលិត ឬក៏ធ្វើជាស្រែចម្ការដើម្បីទទួលបាននូវផលជាស្រូវនោះ ជាអង្ករនោះ ។ ក្រោយមកគណៈអចិន្ត្រៃយ៍ក៏បានសម្រេចថា ប្រជាជនចំនួនជាងកន្លះលាន គួរតែត្រូវបញ្ជូនទៅភូមិភាគពាយ័ព្យ ហើយឲ្យធ្វើការនៅក្នុងសហករណ៍កសិកម្ម នៅក្នុងភូមិភាគនៃពាយ័ព្យនេះ ហើយរយៈពេលខ្លីក្រោយមក ការបញ្ជូនប្រជាជនទ្រង់ទ្រាយធំ ដែលភាគច្រើនជាប្រជាជនថ្មីដែលទើបត្រូវបានជម្លៀសចេញពីភ្នំពេញ និងទៅតាមទីប្រជុំផ្សេងៗត្រូវបានបញ្ជូនពីភូមិភាគបូព៌ា ពីភូមិភាគកណ្ដាល និងពីភូមិភាគអាគ្នេយ៍ទៅភូមិភាគពាយ័ព្យ ។ ហើយពួកគេត្រូវបានយកទៅទម្លាក់នៅលើដីដែលមានគ្មានជីជាតិនៅកណ្ដាលព្រៃភ្នំ ដែលមិនមានជម្រក មិនមានអាហារ និងមិនមានសម្លៀកបំពាក់ ឬក៏ឧបករណ៍ ហើយត្រូវបានប្រាប់ថា ឲ្យធ្វើស្រូវនៅទីនោះ ។ នេះប្រហែលជាសកម្មភាពនៃការអនុវត្តនយោបាយមួយដែលមានមហន្តរាយបំផុត ដែលមានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះដោយមិនមានការគាំទ្រ ហើយពួកគេត្រូវបានបញ្ជូនទៅភ្លាមៗ ។ ប្រជាជនទាំងអស់ទាំងនុ៎ង ចាប់ផ្ដើមអត់អាហារ មានការឈឺ ហើយនិងដោយសារការខ្វះអាហារ ហើយត្រូវធ្វើការនោះហើយត្រូវបានស្លាប់ជាច្រើនពាន់នាក់ដែរ ។

[១៦:០៣:៤០]

**ស៖** សូមអរគុណ ។ យើងបានចំណាយមួយតូច ពិភាក្សាអំពីវិធីសាស្ត្រផ្សេងៗគ្នា ដែលគណៈអចិន្ត្រៃយ៍ធ្វើការទំនាក់ទំនងជាមួយនឹងថ្នាក់ក្រោម ។

ចំណុចមួយ ដែលខ្ញុំចង់បានពីលោកៗ គ្រេក អេតធេសាន់ ពីលើបញ្ហានេះ ថាតើលោកអាចប្រាប់យើងខ្ញុំបានទេ អំពីវិធីសាស្ត្រជាទូទៅដែលគេប្រើទៅតាមវិធីសាស្ត្រមួយៗដែលសម្រាប់ធ្វើការទាក់ទងៗទៅនឹងមាគ៌ានយោបាយក្នុងការកម្ទេចសត្រូវនោះ?

ខ្ញុំសង្ឃឹមថា លោកយល់ពីសំណួររបស់ខ្ញុំ ពីព្រោះស្តាប់ទៅវៀងស្មុគស្មាញបន្តិច ។

**ឆ៖** បាទ, លោកសហព្រះរាជអាជ្ញា ។ ខ្ញុំយល់ថា ខ្ញុំយល់សំណួររបស់លោកហើយ ។

លោក លោកស្រីចៅក្រម និងភាគីទាំងអស់ នឹងអាចរកមើលឃើញនៅក្នុងបញ្ជីឯកសារនេះ ហើយបានពិភាក្សាផងដែរនៅក្នុងរបាយការណ៍របស់ខ្ញុំ អំពីរចនាសម្ព័ន្ធនៃកម្ពុជាប្រជាធិបតេយ្យដោយមានឧទាហរណ៍ជាច្រើន បង្ហាញអំពីសារទូរលេខ និងរបាយការណ៍ផ្សេងៗដែលត្រូវបានបញ្ជូនពីភូមិភាគនានាទៅមជ្ឈិមបក្ស ហើយបានរៀបរាប់ពីការអភិវឌ្ឍន៍ នៅក្នុងតំបន់ នៅក្នុងភូមិភាគ នីមួយៗនោះ ។ ជាទូទៅរបាយការណ៍នេះ និយាយអំពីបញ្ហាសន្តិសុខ ផលិតផលផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍន៍នៅក្នុងការចាត់តាំងនៅក្នុងអង្គការ ។ នៅក្នុងឧទាហរណ៍ជាទូទៅទាក់ទងទៅនឹងរបាយការណ៍បែបនេះគឺជាទូទៅមានប្រាំទំព័រ ដែលនិយាយអំពីបញ្ហាសត្រូវផ្ទៃក្នុង និងវិធានការដែលត្រូវបានធ្វើ ទាក់ទងទៅនឹងសត្រូវផ្ទៃក្នុងនោះ ។ ប្រហែលជាមានមួយទំព័រទៀតនៃរបាយការណ៍នោះ និយាយអំពីផលិតផលផ្នែកសេដ្ឋកិច្ច ហើយប្រហែលជាកន្លះទំព័រនៃរបាយការណ៍នោះនិយាយអំពីការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច។

ទម្រង់នៃរបាយការណ៍នេះគឺធ្វើឡើងដដែលៗ នៅក្នុងការប្រាស្រ័យទាក់ទងគ្នាពីគ្រប់ភូមិភាគទាំងអស់ផ្ញើមកមជ្ឈិមបក្ស ។ ហើយទៅតាមទស្សនៈពីអ្នកដែលធ្វើការវិភាគ គឺអាចធ្វើឡើងស្មើថាថ្នាក់ដឹកនាំមជ្ឈិមបក្សបានយល់ថា មជ្ឈិមបក្សគឺចាប់អារម្មណ៍បំផុតតែទៅលើចំណុច ឬក៏ប្រធានបទទាក់ទងទៅនឹងសត្រូវផ្ទៃក្នុង ជាជាងបញ្ហាទាក់ទងទៅនឹងបញ្ហាផលិតផល ឬក៏ទាក់ទងទៅនឹងបញ្ហានានាទៀត ។

**ស៖** សូមអរគុណ លោកបណ្ឌិត អេតធេសាន់ ។ ប្រហែលជាលោកអាចយល់ថា ខ្ញុំអាចសួរនូវសំណួរបន្ទាប់នេះទៀតហើយ ដែលទាក់ទងអំពីការប្រាស្រ័យទាក់ទងពីថ្នាក់ក្រោមឡើងទៅថ្នាក់លើវិញ គឺមានន័យថា ពីថ្នាក់តំបន់ពីភូមិភាគ និងពីស្រុក និងពីអង្គការរដ្ឋបាល ឬក៏យោធាផ្សេងៗទៀតទៅមជ្ឈិមបក្ស ។ ហើយយើងខ្ញុំចង់សួរទៅលោកបន្តិចថា តើលោកអាចពិភាក្សាបានទេ អំពីប្រព័ន្ធនៃការធ្វើសេចក្តីរាយការណ៍ជាទូទៅ ទៅកាន់មជ្ឈិមបក្សនោះ? ហើយប្រហែលជាលោកអាចយោងទៅលើឯកសារលេខ៣៧ គឺសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្ស ទាក់ទងទៅនឹងបញ្ហាផ្សេងៗមួយចំនួន

គឺការពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ មកនោះ ។ ខ្ញុំចង់លើកបញ្ជាក់អំពីបញ្ហានៃការធ្វើសេចក្តីរាយការណ៍ពីថ្នាក់ក្រោមទៅមជ្ឈិមបក្ស ។

[១៦:០៨:៣៧]

**ឆ៖** បាទ, លោកសហព្រះរាជអាជ្ញាពិតជាបាន ។ លក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា ត្រូវការជាក់លាក់ថា ឋានៈនីមួយៗនៅក្នុងបក្ស ត្រូវរាយការណ៍ជាទៀងទាត់ទៅថ្នាក់លើបន្ទាប់ ។ នៅក្នុងឯកសារដែលលោកបានលើកឡើងអម្បាញ់មិញនេះ គឺឯកសារថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៧៦ គឺជាសេចក្តីសម្រេចរបស់គណៈមជ្ឈិម ស្តីអំពីបញ្ហាផ្សេងៗមួយចំនួននោះ ហើយខ្ញុំគិតថាយើងបានលើកលេខ ERN នៃឯកសារនេះហើយ ដោយសារឯកសារនេះមាននៅក្នុងសំណុំរឿងរួចទៅហើយ ខ្ញុំមិនចាំបាច់លើកឡើងទៀតទេ ។ នៅក្នុងឯកសារនេះ គណៈមជ្ឈិម គណៈអចិន្ត្រៃយ៍បានដាក់នៅដំណាក់កាលជាទៀងទាត់ទាក់ទងទៅនឹងតម្រូវការនៃការធ្វើរបាយការណ៍ជាទៀងទាត់នោះ ហើយបានរៀបរាប់អំពីរបបនៃការធ្វើសេចក្តីរាយការណ៍ជាប្រចាំ ។ ហើយជាការពិតណាស់នៅពេល ដែលលោកពិនិត្យមើលឯកសារនោះ ដែលថាយើងបានទទួល លោកអាចឃើញថានូវទម្រង់នៃការធ្វើរបាយការណ៍ជារៀងរាល់សប្តាហ៍ពីភូមិភាគ ទៅមជ្ឈិមបក្ស ។ ហើយរបាយការណ៍មួយដែលបានរាយការណ៍ពីភូមិភាគទៅមជ្ឈិមនោះ បានរៀបរាប់អំពីរបាយការណ៍នៃរបប នៃការរាយការណ៍ផ្ទៃក្នុងរបស់ខ្លួនផងដែរ ។

ខ្ញុំអាចរំឮកបាន អំពីរបាយការណ៍មួយ ប៉ុន្តែ ខ្ញុំមិនអាចចាំឲ្យបានច្បាស់លាស់នូវលេខឯកសារនោះទេ ពីព្រោះនៅក្នុងរបបមួយដែលមាននៅក្នុងភូមិភាគនោះ របាយការណ៍គឺធ្វើឡើងរៀងរាល់ដប់ថ្ងៃម្តង មិនមែនមួយសប្តាហ៍ម្តង ដូចផ្ញើទៅមជ្ឈិមបក្សទេ ។

**ស៖** សូមអរគុណ ។ ទៅតាមអ្វីដែលលោកបានរៀបរាប់នោះ គឺការទាក់ទងទៅនឹងលក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា ដែលគោលការណ៍ទូទៅរបស់លក្ខន្តិកៈនោះ គឺទំនាក់ទំនង គឺមានន័យទំនាក់ទំនងទៅថ្នាក់លើបន្ទាប់នៃថ្នាក់នោះ ។ នៅកថាខណ្ឌ៧២ នៃរបាយការណ៍របស់លោកៗបានរៀបរាប់ថា នៅក្នុងករណីមួយចំនួន តំបន់តាមធ្វើការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយមជ្ឈិមបក្ស ហើយមិនធ្វើការទាក់ទងទៅភូមិភាគទេ ហើយលោកក៏បាននិយាយផងដែរថា ការប្រាស្រ័យទាក់ទងនេះ ដូចជាមានលក្ខណៈសាមញ្ញធម្មតាជាងទាក់ទងទៅនឹងបញ្ហាសន្តិសុខ ។ តើលោកអាចពន្យល់បានទេ ហេតុអ្វីបានជាលោកធ្វើការសន្និដ្ឋានបែបនេះ? ឬក៏លោកធ្វើការសន្និដ្ឋានបែបនេះដោយវិធីណា?

[១៦:១២:០៨]

**ឆ៖** បាទ, ពិតជាបានលោកសហព្រះរាជអាជ្ញា ។ ឯកសារផ្សេងៗដែលយើងមានន៉ុង ហាក់បីដូចជាបង្ហាញថា ទោះបីជាបញ្ហាទូទៅ ការប្រាស្រ័យទាក់ទងត្រូវបានធ្វើឡើង តាមរយៈបណ្តាញដែលបង្កើតមាននៅក្នុងអង្គការនៃបក្សកុម្មុយនីស្តកម្ពុជា ។ យ៉ាងណាក៏ដោយ ក៏ហាក់បីដូចជាមានការបង្ហាញថា មជ្ឈិមបក្សដែលជាឋានៈខ្ពស់ជាងគេនៅក្នុងបក្សហ្នឹង គឺថាមិនមានការកម្រិតសិទ្ធិរបស់ខ្លួនក្នុងការធ្វើតាមលំដាប់លំដោយនៃការធ្វើសេចក្តីរាយការណ៍នោះទេ ។ ហើយជាញឹកញាប់ ពួកគេបានធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងថ្នាក់ក្រោមដើម្បីទទួលបាននូវព័ត៌មាន ឬក៏ដើម្បីចេញនូវសេចក្តីណែនាំនយោបាយជាក់លាក់ណាមួយ ។ ជាពិសេស ដើម្បីធ្វើឲ្យមានបញ្ហាពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខផ្ទៃក្នុង ដូចជាការប្រមូលព័ត៌មាន អំពីបុគ្គលជាក់លាក់ណាមួយ ធ្វើការផ្លាស់ប្តូរនៅក្នុងថ្នាក់ដឹកនាំ ថ្នាក់ក្រោម ឬមួយការរៀបចំ ការសម្រិតសម្រាំង ។

**ស៖** សូមអរគុណ ។ ឥឡូវនេះ ខ្ញុំចង់និយាយពីប្រធានបទមួយផ្សេងទៀត ទាក់ទងទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា តើលោកអាចជួយប្រាប់ដល់យើងខ្ញុំបានទេ លោកបណ្ឌិត អេតឆេសាន់ ថាតើមានកំណត់ហេតុអង្គប្រជុំប៉ុន្មានដែលបាននៅសល់ពីអង្គប្រជុំដែល សុន សេន បានធ្វើក្នុងនាមគាត់ជាប្រធានអគ្គសេនាធិការ ជាមួយនឹងលេខាទាំងអស់ និងអនុលេខានៃកងពល និងកងវរសេនាធំឯករាជ្យផ្សេងៗ? ប្រហែលជាលោកអាចយោងទៅលើកថាខណ្ឌមួយនៅក្នុងរបាយការណ៍របស់លោកនោះ គឺកថាខណ្ឌ ១១៨ ។

**ឆ៖** សូមអរគុណ លោកសហព្រះរាជអាជ្ញា ។ ពីមុនមក ខ្ញុំបាននិយាយយោងនៅក្នុងសក្ខីកម្មរបស់ខ្ញុំនៅចំពោះមុខអង្គសវនាការនេះ នូវឯកសារដែលជាទូទៅមានចំណងជើងថា "អង្គប្រជុំនៃមេបញ្ជាការ និងអនុមេបញ្ជាការកងពល និងមេបញ្ជានៃកងវរសេនាធំឯករាជ្យ" ។ យ៉ាងហោចណាស់ យើងមានឧទាហរណ៍ចំនួន១៣ នៃកំណត់ហេតុអង្គប្រជុំបែបនេះ ។ ហើយជាទូទៅ អង្គប្រជុំនោះគឺថាបានកើតមានឡើងជាញឹកញាប់ នៅក្នុងដំណាក់កាលណាមួយនៃរបបនោះ ជួនកាលអាចធ្វើឡើងជាមួយសប្តាហ៍ម្តង ដែលពេលនោះមេដឹកនាំជាន់ខ្ពស់នៃកងទ័ពនៃបដិវត្តន៍កម្ពុជា នឹងធ្វើការប្រជុំគ្នានៅអគារអគ្គសេនាធិការ ដែលជាការិយាល័យរបស់ សុន សេន ដើម្បីធ្វើការរាយការណ៍អំពីស្ថានភាពនៅតាមតំបន់ប្រតិបត្តិការរបស់ខ្លួន ហើយនិងដើម្បីទទួលនូវសេចក្តីណែនាំពី សុន សេន ។

[១៦:១៦:២១]

**ស៖** សូមអរគុណ ។ ខ្ញុំក៏ចង់សូមឲ្យលោកធ្វើការពិភាក្សាផងដែរ អំពីអង្គប្រជុំដែលបានធ្វើឡើងរវាង សុន សេន ជាមួយនឹងលេខា និងអនុលេខាមួយចំនួន ដែលត្រូវបានជ្រើសរើសមកពីកងពល និងកងវរសេនាធំឯករាជ្យ ។

ហើយថាតើមូលហេតុអ្វីនៃការជ្រើសរើសលេខា ឬក៏អនុលេខាមួយចំនួនតែប៉ុណ្ណោះ សម្រាប់អង្គប្រជុំបែបនោះ?

**ឆ៖** បាទ, ពិតជាបានលោកសហព្រះរាជអាជ្ញា ។ ទៅតាមឯកសារផ្សេងៗអាចបង្ហាញឲ្យយើងឃើញថា វាជាស្ថានភាពទូទៅទាក់ទងទៅនឹងការប្រជុំជាច្រើនរបស់អគ្គសេនាធិការក្នុងការនាំមេដឹកនាំមកពីកងពលមជ្ឈិមផ្សេងៗ ដើម្បីមកប្រជុំនៅឯកអគ្គសេនាធិការ ។ ដែល សុន សេន ក៏បានធ្វើការរៀបចំអង្គប្រជុំផ្សេងៗជាមួយនឹងបុគ្គលិកជាន់ខ្ពស់នៃកងពលនីមួយៗ ឬមួយក៏កងវរសេនាធំឯករាជ្យនីមួយៗ ដើម្បីធ្វើការរៀបរាប់អំពីគោលនយោបាយផ្សេងៗ ជាក់លាក់ណាមួយ ដែលគាត់ចង់ធ្វើឲ្យមានការអនុវត្ត ដើម្បីឲ្យគេយកទៅអនុវត្ត ជាពិសេសនៅក្នុងតំបន់ ឬក៏ភូមិភាគជាក់លាក់ណាមួយនោះ ។

អង្គប្រជុំប្រភេទនេះ គឺអង្គប្រជុំជាមួយនឹងកងពលនីមួយៗ ជាញឹកញាប់ទាក់ទងទៅនឹងតែបញ្ហាសន្តិសុខតែប៉ុណ្ណោះ ហើយមិនមែនទាក់ទងទៅនឹងបញ្ហាផ្សេងៗជាច្រើន ដែលជាទូទៅដែលគេធ្វើឡើងនៅក្នុងអង្គប្រជុំធំៗ ដែលរួមមានទាំងបញ្ហាសន្តិសុខ បញ្ហាសេដ្ឋកិច្ច ផលិតផលជាដើមនោះ និងទាក់ទងទៅនឹងបញ្ហាគោលនយោបាយទូទៅ ។

**ស៖** មុននឹងខ្ញុំឲ្យលោកធ្វើការបង្ហាញអំពីចំណុចនេះ តើខ្ញុំអាចឲ្យលោកធ្វើការពិភាក្សាប្រាប់ពួកយើងខ្ញុំ អំពីធាតុដើមនៃការប្រាស្រ័យទាក់ទងគ្នារវាងយោធាបានឬទេ? ហើយថាតើជាទូទៅ តើការប្រាស្រ័យទាក់ទងហ្នឹង គឺតាមរយៈខ្សែបណ្ដោយឬ? ឬមួយក៏មានការប្រាស្រ័យទាក់ទងតាមរយៈខ្សែទទឹងផង នៅរវាងកងពលនីមួយ ឬមួយក៏កងវរសេនាធំរាជ្យនីមួយៗនោះ? តើលោកយល់អ្វីដែលខ្ញុំចង់និយាយទេ?

**ឆ៖** បាទ, ខ្ញុំយល់ លោកសហព្រះរាជអាជ្ញា ។ ជាទូទៅ នៅក្នុងស្ថាប័នក្បាលម៉ាស៊ីនរដ្ឋបាលយោធា និងនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ការប្រាស្រ័យទាក់ទងគ្នា គឺកំណត់បំផុត តែតាមរយៈខ្សែបណ្ដោយតែប៉ុណ្ណោះ ។ ហើយគឺមានការកំណត់ឲ្យអនុវត្ត ការប្រាស្រ័យទាក់ទងតាមខ្សែបណ្ដោយនេះជាដាច់ខាត ។ ជាឧទាហរណ៍ ប្រសិនបើថ្នាក់ដឹកនាំនៃតំបន់ពីរ ដែលនៅជាប់គ្នា ដែលស្ថិតនៅក្នុងភូមិភាគផ្សេងពីគ្នា ហើយមានបញ្ហានោះ ដែលត្រូវធ្វើការពិភាក្សាគ្នា ពួកគេមិនអាចធ្វើការ

ប្រាស្រ័យទាក់ទងគ្នាផ្ទាល់បានទេ តាមរយៈខ្សែទទឹងទេនោះ ។ មានន័យថា លេខាតំបន់នោះមិនអាចធ្វើការប្រាស្រ័យទាក់ទងគ្នាបានទេ ក៏ប៉ុន្តែ ពួកគេត្រូវធ្វើការប្រាស្រ័យទាក់ទង តាមរយៈថ្នាក់ដឹកនាំភូមិភាគរបស់ខ្លួន ហើយនិងឡើងទៅដល់មជ្ឈិមបក្ស ។ ដូច្នេះហើយមានន័យថា គឺមជ្ឈិមបក្ស គឺជាទីចំណុចកណ្តាលសម្រាប់អង្គការចាត់តាំងទាំងមូល ដែលជាការិយាល័យកណ្តាលដែលមានទូរស័ព្ទនៅទីនោះផងដែរ ។ ដូច្នេះហើយមជ្ឈិមបក្ស គឺជាស្ថាប័នតែមួយគត់ដែលបានយល់ដឹងពីអ្វី ស្ថានភាពទាំងអស់នៅដែលកើតមានឡើងនៅក្នុងប្រទេស ។ ហើយជាការពិតណាស់ជាញឹកញាប់ នៅក្នុងចម្លើយសារភាពនៅស-២១ មានការសារភាព ដែលថា មនុស្សបានធ្វើប្រាស្រ័យទាក់ទង ក្រៅពីការប្រាស្រ័យទាក់ទងរយៈបណ្តោយនោះ ហើយត្រូវបានគេចោទថាជាមនុស្សក្បត់ជាតិ ។

ការប្រាស្រ័យទាក់ទងរយៈខ្សែបណ្តោយនេះ គឺត្រូវការឲ្យធ្វើជាហ្មត់ចត់បំផុតជាពិសេស នៅក្នុងរចនាសម្ព័ន្ធយោធា ។

**លោក អាឡិចសាន់ឌឺ ប៊ិត៖**

សូមអរគុណ ។ ខ្ញុំចង់ឲ្យលោកធ្វើការពិភាក្សាបន្តិចអំពីស-២១ ទាក់ទងទៅនឹងការប្រាស្រ័យបណ្តាញទំនាក់ទំនង ដែលលោកទើបតែបានរៀបរាប់អម្បាញ់មិញនេះ ។ ហើយសុំឲ្យលោកពិនិត្យមើលទៅលើកំណត់ហេតុនៃអង្គប្រជុំមួយចំនួន ដែលលោកបានយោងរួចមកហើយ គឺឯកសារលេខ៣៥ នៅក្នុងឧបសម្ព័ន្ធរបស់លោក ដែលជាកំណត់ហេតុនៃអង្គប្រជុំរវាងលោក តាល់ គឺ រវាងកងពល២៩០ និង ១៧០ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ៧៦ នោះ ។

ហើយខ្ញុំចង់ដឹងថា តើលោកប្រធានប្រសិនបើយើងអាចដាក់បញ្ចាំងលើអេក្រង់ នូវឯកសារជាភាសាខ្មែរ ហើយលោក ហ្វូដ គាត់នឹងមានឯកសារនេះនៅលើអេក្រង់កុំព្យូទ័ររបស់គាត់ ដើម្បីឲ្យធ្វើការបញ្ចាំងនោះ ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញា អាចត្រូវការចំណាយពេលពេលវេលាច្រើនទេ ក្នុងការធ្វើសំណួរដែលពាក់ព័ន្ធជាមួយនឹងឯកសារ ដែលត្រូវស្តាយក្រោយនេះ?

**លោក អាឡិចសាន់ឌឺ ប៊ិត៖**

សូមអរគុណ ។ ខ្ញុំក៏បានកត់សម្គាល់លើពេលវេលាផងដែរ ប្រហែលជាខ្ញុំត្រូវការពេលវេលាតែប្រាំនាទីតែប៉ុណ្ណោះ ។

[១៦:២៣:៣៣]

**ប្រធានអង្គជំនុំ៖**

ដូច្នេះ សូមអញ្ជើញ ហើយសូមអនុញ្ញាតតាមបច្ចេកទេសដែលមាន ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ ។ សូមលោកប្រធានបង្គាប់ឲ្យខាងផ្នែកសោតទស្សន៍ បញ្ចាំងអេក្រង់កុំព្យូទ័ររបស់សហសេវិករបស់ខ្ញុំ នៅលើអេក្រង់ធំ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍ អនុវត្តតាមសំណូមពររបស់សហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

តើយើងអាចមានកំណាត់សម្គាល់ចុងទំព័របានទេ? ទាក់ទងទៅនឹងឯកសារនេះ ដែលជាឯកសារមួយនៅក្នុងកំណត់ហេតុរបាយការណ៍របស់លោក អេតធេសាន់ ។

ខ្ញុំចង់បាននូវលេខ *ហ្វូតណូត* ដើម្បីធ្វើការបញ្ជាក់ថា របាយការណ៍នេះពិតជាមាននៅក្នុងរបាយ-ការណ៍របស់គាត់មែន ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខាងមេធាវីការពារក្តី សូមរង់ចាំតែបន្តិច ។

គឺលេខ *ហ្វូតណូត* ២៨៣ ។ ខ្ញុំចង់ឲ្យលោក ហ្វូដ បកត្រឡប់ទៅរកឯកសារភាសាអង់គ្លេសវិញ ។ បើសិនជាលោកបង្វិលឡើងទៅលើ ខាងដើមនៃទំព័រនេះ ហើយខ្ញុំនឹងបង្ហាញឯកសារនេះដោយខ្លីជាភាសាអង់គ្លេស ។ ឯកសារនេះ គឺឯកសារចុះនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ៧៦ គឺជាកំណត់ហេតុនៃការប្រជុំរបស់សមមិត្ត តាល់ កងពល២៩០ និងកងពល១៧០ ។ ហើយនៅខាងក្រោមមកទៀត ទាក់ទងទៅនឹងផ្នែកដែលមាននៅក្នុងប្រអប់នេះ ខ្ញុំនឹងអានខ្លីៗ សមមិត្ត ឌុច បានមានទស្សនៈថា ក្រោយប្រជុំ--

**លោក ហ្វ្រង់ស្វ័រ រូ៖**

បើសិនជាលោកចង់អានឯកសារ សូមឲ្យលោកអានឯកសារដើម កុំឲ្យអានឯកសារ ដែលជាឯកសារបកប្រែនោះ ។

ខ្ញុំគិតថាឯកសារនេះ មានជាភាសាខ្មែរ ។ ដើម្បីឲ្យកំណត់សម្គាល់នេះ ជាភាសាខ្មែរ តើអ៊ីចឹងយើងត្រូវការអានឯកសារបកប្រែ ធ្វើអីចុះ?

[១៦:២៧:៣៤]

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

បើអ៊ីចឹង គឺថាយើងនឹងដាក់ជាភាសាខ្មែរ ។ ខ្ញុំសូមឲ្យលោកប្រធានអនុញ្ញាត ឲ្យក្រឡាបញ្ជីធ្វើការអានអត្ថបទជាភាសាខ្មែរ នៅពេលដែលមានចំៗនិយាយថា សមមិត្ត ឌុច មានមតិ ហើយអានរហូតដល់លេខពីរ គឺទាក់ទងទៅនឹងចំណុចមួយក្បែរ និយាយអំពីបញ្ហាប្រតិបត្តិការ ។

សុំទោសលោកប្រធាន គឺថាយើងមិនចាំបាច់ឲ្យអានឈ្មោះ ដែលមាននៅក្នុងប្រអប់នេះទេ គឺគ្រាន់តែឲ្យអានអត្ថបទតែប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

អានចំណុចណាមួយ? ចំណុចទី២ ហ្នឹងអាននៅក្នុងរង្វង់ក្រហមហ្នឹង លើកលែងតែឈ្មោះមនុស្សមែនទេ?

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ប្រហែលជាងាយស្រួលប្រសិនបើសិនជាអត្ថបទទាំងអស់ ដែលមាននៅក្នុងប្រអប់ហ្នឹងត្រូវបានអាននោះ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជី តើមានទេ? អាន, សែ កុលវុឌ្ឍី អាននូវអត្ថបទដែលមាននៅក្នុងប្រអប់បន្ទាត់ពណ៌ក្រហមទាំងស្រុង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សមមិត្ត ឌុច មានមតិ៖ ក្រោយប្រជុំសមមិត្ត សុខ និង តាត កងពល១៧០ បានឯកភាពគ្នាត្រូវស្នើយកឈ្មោះ ២៩ នាក់ ទៀតគឺ៖ ១) ហួត ប៉េងឡេង វាយអង្គលីលេខ, ២) ថាច់ សាន ភស្តុភារ,៣) ថោង សាផៃ, ៤) សួ សុន, ៥) ខឹម យ៉ាន់, ៦) ងួន ទូច, ៧) នៅ ផុន, ៨) ខៀវ សាត, ៩) យក សាំង, ១០) ឯម សុត, ១១) ហួត សំអែល, ១២) ប៉ែន ពេញ, ១៣) គ្រឿន, ១៤) អ៊ុំង សុន, ១៥) សុខ ខៃ, ១៦) កែន ង៉ុន, ១៧) ទិត សាមិន, ១៨) សាម៉េត, ១៩) គង់ សឿន, ២០) កែ អឿន, ២១) ឡុង សារ៉េត, ២២) កែវ សុខ, ២៣) ចាន់ គួន, ២៤) កង សារ៉េត, ២៥) គី សុផាត, ២៦) សុខ ពៅ, ២៧)

សិន សុង, ២៨) ពុត សុខន, ២៩) ប្រាក់ ផល្លី ។ ឈ្មោះស្នើនេះគឺស-២១ និងកងពល១៧០ ប្រជុំគ្នាសម្រេចក្រៅពី១១ នាក់ ដែលប្រជុំសម្រេចពីថ្ងៃ១៥ ខែ៩ ។

១) ឈរលើហេតុផលបញ្ជាក់របស់ស-២១ និងកងពលឃើញសកម្មភាពជាក់ស្តែងជាបន្តបន្ទាប់ ព្រមទាំងឈរលើគោលការណ៍អង្គការកំណត់ ពួកខ្មែរស្រឡាយ អាចក្រី ត្រូវយកអង្គប្រជុំយល់ស្រប សម្រេចយកឈ្មោះអ្នកទាំង២៩នាក់នេះទៀត ។

[១៦:៣២:១៧]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ លោកស្រី ក្រឡាបញ្ជី ។

បន្ទាប់មកទៀត គឺខ្ញុំចង់ឲ្យអានអត្ថបទបន្ទាប់ទៀត ដែលស្ថិតនៅក្នុងប្រអប់ក្រហម ។

**ប្រធានអង្គជំនុំ៖**

អានចំណុចមួយទៀត ដែលមានបន្ទាត់ក្រហមគូសព័ទ្ធជុំវិញនៅខាងក្រោមបង្អស់នេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

១) ត្រូវធ្វើតាមពិសោធន៍របស់យើង ដែលបានផ្តាច់យកពួកនេះជាបន្តបន្ទាប់ ធ្វើម៉េចកុំឲ្យអង្គការជ្រួលច្របល់ ដើម្បីកុំឲ្យអង្គភាពជ្រួលច្របល់ ភ្ជាប់ ក្តាប់អង្គភាពឲ្យជាប់ក្នុងដៃ និងរក្សាការសម្ងាត់ឲ្យបានល្អ ។ ជាក់ស្តែង ពិគ្រោះពិភាក្សាវិធីដំណើរការជាមួយស-២១ ដើម្បីយកនិងចាត់តាំងគ្រប់គ្រងអង្គភាពក្នុងពេលដកពួកវាចេញ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ហើយជាជាទីបញ្ចប់ហ្នឹង គឺសូមលោកប្រធានអនុញ្ញាតឲ្យក្រឡាបញ្ជី អាននូវអត្ថបទនៅក្នុងប្រអប់ពណ៌ក្រហមទីបី ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអានបន្ត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

១) ខាងកងពល២៩០ ត្រូវស-២១ និងកងពលសងខាងគ្នា ចាប់យកពីកន្លែងដាក់ឡានតែម្តង--សហការគ្នាចាប់យកពីកន្លែងដាក់ឡានតែម្តង ។

២) ខាងកងពល១៧០ ត្រូវស-២១ និងកងពលពិគ្រោះគ្នាយកវិធានការល្អិតជាក់ស្តែង ដើម្បី

យកពួកទាំង៤0នាក់ ។

[១៦:៣៤:៣៤]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំមានសំណួរចុងក្រោយមួយ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំសូមទោស ខ្ញុំយល់ថា មានបញ្ហាបកប្រែ ។ សម្រាប់ខ្ញុំ ខ្ញុំយល់ថា មានចំណុចសំខាន់ណាស់ ខ្ញុំបានឮថា នៅក្នុងការបកប្រែដែលខ្ញុំបានឮ ទាក់ទងទៅនឹងកងពល២៩០ ហើយដែលថា កងពល ហើយនិងស-២១ ត្រូវសហប្រតិបត្តិការគ្នា។ ពីព្រោះអីទៅតាមការបកប្រែគឺថា បុគ្គលទាំងអស់ត្រូវចាប់ ហើយនិងត្រូវដឹកជញ្ជូនតាមឡាន ។ អ៊ីចឹងតើឃ្លាហ្នឹងឯង មាននៅក្នុងជាភាសាខ្មែរទេ ឬក៏បកប្រែហ្នឹង បកប្រែលើសពីអត្ថបទដែលមាននៅក្នុងអ្វីដែលលោកស្រីក្រឡាបញ្ជីបានអាន? ពីព្រោះអ្វីដែលខ្ញុំបានអាន ហ្នឹង ទាក់ទៅនឹងកងពល២៩០ ដែលថាស-២១ នឹងកងពលហ្នឹងឯង គឺត្រូវសហប្រតិបត្តិការគ្នា ។ ខ្ញុំបានឮតែប៉ុណ្ណឹងទេ ខ្ញុំអត់មានបានឮអំពីការចាប់ និងការបញ្ជូនតាមរថយន្តនោះទេ ។ ខ្ញុំចង់ធ្វើការបញ្ជាក់អំពីចំណុចនេះថាតើកាបកប្រែនេះមាននៅក្នុងអត្ថបទជាភាសាខ្មែរដែរឬក៏អត់? តើលោកប្រធាន អាចឲ្យលោកក្រឡាបញ្ជី លោកស្រីក្រឡាបញ្ជីអាន កថាខណ្ឌពីរចុងក្រោយហ្នឹងទៀតបានទេ បើសិនជាអាច?

**ប្រធានអង្គជំនុំ៖**

អាចធ្វើបាន ក្រឡាបញ្ជីអានចំណុចទីមួយ និងទីពីរ នៅក្នុងបន្ទាត់គូសរង្វង់ក្រហមនេះ ម្តងទៀតឲ្យច្បាស់លាស់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

១) ខាងកងពល២៩០ ត្រូវ ស-២១ និងកងពលសហការគ្នាចាប់យកពីកន្លែងដាក់ឡានតែម្តង ។

២) ខាងកងពល១៧០ ត្រូវ ស-២១ និងកងពលពិគ្រោះគ្នាយកវិធានការល្អិត ជាក់ស្តែង ដើម្បីយកពួកទាំង៤0នាក់ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ខ្ញុំនឹងផ្តល់លេខ ERN នៃឯកសារជាភាសាបារាំង គឺលេខ 00224409 ដែលជាអត្ថបទជាភាសាបារាំង ។ ហើយអ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍នោះថា ខ្ញុំចង់ដឹងថា តើអ្វីដែលត្រូវបាន

បកប្រែជាភាសាបារាំង? ហើយខ្ញុំចង់ដឹងថា តើការបកប្រែជាភាសាបារាំងហ្នឹង វាស៊ីគ្នាទៅនឹងអត្ថបទដើមដែរឬទេ? នេះជាចំណុចបារម្ភរបស់ខ្ញុំនោះ ។

ដូច្នេះហើយ ខ្ញុំចង់គិតយើងគួរតែពឹងអាស្រ័យលើតែឯកសារដែលជាច្បាប់ដើម ហើយបើសិនជាឯកសារច្បាប់ដើមនិយាយអំពីក្រុមឡាន ហើយនិងការចាប់ហើយដឹកជញ្ជូនតាមឡាននោះ គឺថាច្បាស់លាស់ហើយ នេះជាសំណួរដែលខ្ញុំចង់សួរនោះ ។

[១៦:៣៨:១៣]

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

លោកប្រធាន តើយើងបង្ហាញអំពីឯកសារដើមបានទេ? ខ្ញុំបានយល់អំពីពេលវេលានៃការធ្វើអន្តរាគមន៍របស់មេធាវីការពារក្តីនោះ ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអាចបន្តបានហើយ ដូចយើងផ្អែកលើមូលដ្ឋានដើមនោះ គឺមានគ្រប់សព្វហើយ ហើយពាក្យពេចន៍នៅក្នុងការបកប្រែនេះ ខ្ញុំមិនចេះបារាំងច្បាស់ទេ ក៏ប៉ុន្តែមាន *វ៉ូទុយ* អីនៅហ្នឹងដូចជាច្បាស់លាស់ហើយ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ើត៖**

**ស៖** សូមអរគុណលោកប្រធាន ។ សំណួរចុងក្រោយរបស់ខ្ញុំសម្រាប់សាក្សីអ្នកជំនាញនេះសម្រាប់សប្តាហ៍នេះ គឺថាលោកបណ្ឌិត អេតឆេសាន់ ឥឡូវនេះគឺថា យើងបានឲ្យអានឮនៅក្នុងសាលសវនាការអំពីកំណត់ហេតុនៃអង្គប្រជុំរៀបរាប់អំពីរបៀបដែលស-២១ បានជួបជាមួយនឹងកងពលបានពិភាក្សា និងបានទទួលស្គាល់អ្នកទោស ហើយបានសហប្រតិបត្តិការទៅលើវិធីនៃការចាប់ខ្លួន ។ តើលោកអាចប្រាប់យើងខ្ញុំបានទេ តើអ្វីដែលមានកើតមានឡើងនេះវាស៊ីគ្នាទៅនឹងទិដ្ឋភាពទូទៅដែលលោកបានរៀបរាប់បានទេ ទាក់ទងទៅនឹងការប្រាស្រ័យទាក់ទងតាមរយៈខ្សែបណ្តោយនោះ?

**ឆ៖** បាទ, ពិតជាបានលោកសហព្រះរាជអាជ្ញា ។ ទៅតាមឯកសារនេះអ្នកដែលចូលរួមនៅក្នុងអង្គប្រជុំហ្នឹងដែរគឺ សុន សេន ។ គាត់គឺជាឧបនាយករដ្ឋមន្ត្រីសម្រាប់ខាងការពារជាតិ ហើយនិងជាប្រធានអគ្គសេនាធិការ ហើយនិងជាសមាជិកនៃមជ្ឈិមបក្សនៅក្នុងគណៈឃោធា ។ ដូច្នេះហើយ ជនជាប់ចោទមានការប្រាស្រ័យទាក់ទងជាមួយថ្នាក់លើផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា ហើយក៏ធ្វើការប្រាស្រ័យទាក់ទងតាមរយៈ សុន សេន ជាមួយនឹងកងពលដែលធ្វើប្រតិបត្តិការនៅក្នុង ដើម្បីជាជំនួយនៅក្នុងការ

ប្រតិបត្តិការរបស់ខ្លួន ដែលក្រោយមកក្លាយទៅជាទ្រង់ទ្រាយធំនៃការបោសសម្អាតនៅក្នុងផ្នែកយោធា ទាក់ទងទៅនឹងកិច្ចការរបស់ ចាន់ ចក្រី ផងដែរ ។

**ស៖** ខ្ញុំចង់ធ្វើការបញ្ជាក់បន្តិច នៅក្នុងគំនិតឯកទេសរបស់លោក តើលោកយល់ថា ឯកសារនេះ

ផ្តល់សិទ្ធិពីមជ្ឈិមដែលភាគី ដែលអង្គភាពនីមួយៗអាចធ្វើការប្រាស្រ័យទាក់ទងផ្ទាល់ ឬមួយក៏ ស-២១ អាចធ្វើការទាក់ទងជាមួយអង្គភាពផ្សេងៗនោះបាន ។ តើលោកអាចរៀបរាប់យ៉ាងម៉េចអំពីការទំនាក់ទំនងរវាងអង្គភាព និងស-២១នេះ?

[១៦:៤១:៥០]

**ឆ៖** ដូចសម្រាប់ខ្ញុំៗដូចជាយល់ច្បាស់ថា ប្រតិបត្តិការនេះគឺបានអនុវត្តស្ថិតនៅក្រោមការបញ្ជាផ្ទាល់របស់មជ្ឈិមបក្ស ដែលអនុញ្ញាតឲ្យមានការប្រាស្រ័យទាក់ទងគ្នាបែបគ្នារវាង ស-២១ និងអង្គភាពដែលជាគោលដៅ ដែលជាការចាំបាច់ដើម្បីអនុវត្តនូវផែនការបោសសម្អាត ។

**លោក អាឡិចសាន់ឌឺ បេ៉ត៖**

លោកប្រធានខ្ញុំសូមអភ័យទោសដែលខ្ញុំបានធ្វើលើសពីចំនួនប្រាំនាទី ដែលខ្ញុំបានស្នើលោកឡើងនោះ ប៉ុន្តែខ្ញុំយល់ថា នេះជាចំណុចសំខាន់ដើម្បីធ្វើការបានច្បាស់លាស់ទាំងអស់គ្នា ។

**ប្រធានអង្គជំនុំ៖**

ហើយខាងរូបភាព គឺអាចបង្វិលស្ថានភាពវិញហើយៗដោយថា ពេលវេលាក៏ដល់ពេលត្រូវសម្រាកហើយ ហើយអង្គជម្រះ សូមអរគុណលោកបណ្ឌិត គ្រេក អេតឆេសាន់ ដែលបានចំណាយពេលវេលា និងអត់ធ្មត់នៅក្នុងការផ្តល់សក្ខីនូវចំពោះមុខអង្គសវនាការ ។ ហើយជាការពិតណាស់ តាមដំណើរការសវនាការនេះ គឺមិនទាន់បានដាច់ស្រេចទេនឹងធ្វើបន្តទៅទៀត ហើយដោយសារផែនការហ្នឹងគឺយើងធ្វើតែថ្ងៃច័ន្ទ និងថ្ងៃអង្គារ មានអ្នកជំនាញមួយទៀត ។

[១៦:៤៤:៣៦]

ដោយមានបញ្ហាលើកាលវេលា ដែលត្រូវកំណត់ដោយមូលហេតុសាក្សីមួយទៀត ដែលយើងបានប្រកាសជម្រាបជូនដល់ភាគី អំពីដំណើរការនៃធ្វើសក្ខីកម្មរបស់អ្នកជំនាញដែលចាំបាច់ ដោយសារគាត់មិនមានពេលវេលាសម្រាប់មកធ្វើសវនាការនៅចំពោះមុខអង្គជំនុំជម្រះបានទេ ក្រៅថ្ងៃទី២៥ និងថ្ងៃទី២៦ ។ ដូច្នេះហ្នឹងគឺ ចំពោះការធ្វើសវនាការបន្តលើបណ្ឌិត គ្រេក អេតឆេសាន់ នេះ ដោយសារលោកមានវត្តមាននៅកម្ពុជា នៅភ្នំពេញនេះ ។ អ៊ីចឹង យើងនឹងលៃពេលសមស្របណាមួយដើម្បីធ្វើ

បន្ត ។ ចំណែកឯចាប់សប្តាហ៍ក្រោយនេះ គឺថ្ងៃដើមសប្តាហ៍ យើងធ្វើសក្ខីអ្នកជំនាញដែលចាំបាច់ ដែលគាត់មានពេលវេលាតែពីរថ្ងៃនោះ ។

អ៊ីចឹង ចំពោះលោកបណ្ឌិត គឺសូមរង់ចាំដើម្បីអង្គជម្រះកំណត់កាលវេលាសមស្របណាមួយដែលលៃលកតាមកាលវិភាគដែលមានរួចហើយ ដើម្បីអញ្ជើញលោកមកបន្តសក្ខីកម្មដើម្បីបញ្ចប់ ប៉ុន្តែមិនទាន់បានកំណត់នាពេលនេះទេ ។

ហើយអង្គជម្រះ សូមប្រកាសផ្អាកដំណើរការសវនាការកំណត់ថ្ងៃនេះ ត្រឹមនេះ ហើយសូមអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅថ្ងៃទី ព្រឹកថ្ងៃទី២៥ ឲ្យមុនម៉ោងប្រាំបួន ។ ហើយភាគីដែលពាក់ព័ន្ធក៏ដូចគ្នា ហើយមន្ត្រីតុលាការសម្រួលដល់លោកបណ្ឌិត អ្នកជំនាញ ដើម្បីឲ្យគាត់បានវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:៤៧ នាទី]*